# ព្រះរាជក្រម

នស/រកម/១២០៦/០២៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្ដីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្ដីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ ដែលធ្វើនៅទីក្រុងប្រ៊ុចសែល នាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦
ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំបទ្ទាប់
ប្រមុខរដ្ឋស្ដីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រ/ល.០៦១២.៥០០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

លេខ: ៤៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជីនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦ សជណ.ករច

# សេចក្តីថ្លែងហេតុ

# នៃសេចក្តីព្រាងច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិ ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ

អនុសញ្ញាអន្តរជាតិស្តីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយ ធ្វើនៅទីក្រុងប្រ៊ូសែល ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣។

បុព្វបទ និងខ្លឹមសារសង្ខេបនៃអនុសញ្ញានេះមានដូចតទៅ :

១-សមាជិកភាពកម្ពុជាក្នុងអាស៊ាន(១៩៩៩) អង្គការគយពិភពលោក(២០០១) និងអង្គការពាណិជ្ជកម្មពិភពលោក(២០០៣) បង្ហាញពីការអនុវត្តជាក់ស្តែងនូវនយោបាយសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងចរន្តសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ទន្ទឹមនឹងកាលានុវត្តភាពក៏មានការប្រឈមខ្លះនៅក្នុងដំណើរការនេះ ហើយដែលតម្រូវឱ្យមានការឆ្លើយតប ឱ្យបានទាន់ពេលវេលា ដើម្បីដោះស្រាយ និងគ្រប់គ្រងការប្រឈមទាំងនោះ។

២-អង្គភាពគយ និងរដ្ឋាករកម្ពុជាជាស្ថាប័នឈានមុខដែលមានតួនាទីអនុវត្តនូវកាតព្វកិច្ច និងការសន្យានានា របស់កម្ពុជាពាក់ពន្ធ័នឹងការគ្រប់គ្រងចរន្តពាណិជ្ជកម្មអន្តរជាតិ។ ដើម្បីអនុវត្តតួនាទីនេះឱ្យមានប្រសិទ្ធភាពខ្ពស់ អង្គភាពគយ និងរដ្ឋាករកម្ពុជាត្រូវទទួលយកមកអនុវត្តនូវ ស្តង់ដារអន្តរជាតិ បទពិសោធន៍ និងការអនុវត្តប្រសើរជាអន្តរជាតិ (International Best Practices). ព្រមទាំងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រព័ន្ធគយពិភពលោក។

៣-នៅរយៈពេលចុងក្រោយនេះ ទន្ទឹមនឹងការប្រឈមជាទូទៅក្នុងការគ្រប់គ្រងចរន្តពាណិជ្ជកម្មអន្តរជាតិ មានការប្រឈមថ្មីមួយទៀតបានកើតឡើង ហើយដែលតម្រូវឱ្យមានកិច្ចសហប្រតិបត្តិ

ការឱ្យកាន់តែស្អិតល្មួតឡើង រវាងរដ្ឋបាលគយទាំងអស់នៅលើពិភពលោកនោះ គឺការរួមគ្នាទប់ស្កាត់និងបង្ក្រាបអំពើភេរវកម្មឆ្លងដែន។ ជាការឆ្លើយតបនឹងការប្រឈមនេះ និងដើម្បីជំរុញនិងសម្រួលដល់កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយនៅក្នុងយុគសម័យនេះអង្គការគយពិភពលោកបានអនុម័ត "អនុសញ្ញាអន្តរជាតិស្តីពីជំនួយរដ្ឋបាលទៅវិញទៅមកក្នុងកិច្ចការគយ" (International Convention on Mutual Administrative Assistance in Customs Matters) ដែលជា ឧបករណ៍គតិយុត្តិមួយទំនើប និងឆ្លើយតបនឹងតម្រូវការបច្ចុប្បន្នសម្រាប់ប្រើប្រាស់ដោយរដ្ឋបាលគយទាំងអស់ក្នុងកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរព័ត៌មានក្នុងកម្រិតអន្តរជាតិ ព្រមទាំងពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងចរន្តពាណិជ្ជកម្មអន្តរជាតិ។

៤-គោលបំណងចម្បងនៃអនុសញ្ញាអន្តរជាតិនេះគឺ សំដៅបង្កើនកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយឱ្យកាន់តែជិតស្និទ្ធ និងមានប្រសិទ្ធភាពខ្ពស់ ដោយឈរលើគោលការណ៍បដិការ ក្នុងការជួយគ្នាទៅវិញទៅមក។ ការអនុវត្តអនុសញ្ញានេះនឹងនាំឱ្យមានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការនាំចេញ និងនាំចូល កាត់បន្ថយបទល្មើស និងអំពើរត់ពន្ធគយ បង្ការ និងទប់ស្កាត់ឱ្យបានទាន់ពេលវេលានូវការជួញដូរទំនិញហាមឃាត់ និងជាពិសេសការបង្ការ និងទប់ស្កាត់អំពើភេរវកម្ម។ ការអនុវត្តអនុសញ្ញានេះក៏នឹងជំរុញឱ្យមានការសម្រួលពាណិជ្ជកម្មផងដែរ តាមរយៈការផ្តល់ព័ត៌មានជាមុនអំពីការចេញដំណើរនៃទំនិញ ដែលអនុញ្ញាតឱ្យម្ចាស់ទំនិញអាចបំពេញបែបបទគយមុនពេលទំនិញមកដល់គោលដៅ និងការអនុវត្តប្រពន្ធ័គ្រប់គ្រងហានិភ័យ។

៥-ក្រោយពេលបានចូលជាភាគីនៃអនុសញ្ញាអន្តរជាតិនេះ ប្រទេសជាភាគីនឹងទទួលបានប្រយោជន៍ដែលរួមមាន:

-ផ្លាស់ប្តូរព័ត៌មាន និងស្នើសុំជំនួយដោយស្របច្បាប់ជាមួយបណ្តារដ្ឋបាលគយនៃប្រទេសនានា ដែលជាភាគីនៃអនុសញ្ញានេះ។

-ផ្លាស់ប្តូរព័ត៌មានជាមុនអំពីការចេញដំណើររបស់ទំនិញ ដែលជាផ្នែកមួយក្នុងការអនុវត្តការធានាសន្តិសុខនៃចង្វាក់ពាណិជ្ជកម្មអន្តរជាតិ។

-ដោយឈរលើគោលការណ៍បដិការ ភាគីនៃអនុសញ្ញាត្រូវផ្តល់ និងទទួលការជួយគ្នាទៅវិញទៅមកដែលគ្របដណ្តប់ទូលំទូលាយទៅលើកិច្ចការរដ្ឋបាលគយដែលក្នុងនោះមាន ការជំរុញអនុវត្តច្បាប់ស្តីពីគយ និងច្បាប់ផ្សេងៗទៀតដែលអង្គភាពគយមានតួនាទី និងភារកិច្ចជំរុញអនុវត្ត។

-ចូលរួមជាផ្លូវការទៅក្នុងបណ្តាញគយអន្តរជាតិនៃអង្គការគយពិភពលោក ដែលជាយន្តការសហប្រតិបត្តិការក្នុងការងារគយ (WCO Customs Enforcement Network)។

-ប្រើប្រាស់អនុសញ្ញាអន្តរជាតិនេះជាមូលដ្ឋាន ក្នុងការរៀបចំកិច្ចព្រមព្រៀងទ្វេភាគីស្តីពីការជួយគ្នាទៅវិញទៅមករវាងរដ្ឋបាលគយ។

៦-ការចូលជាភាគីនៃ "អនុសញ្ញាអន្តរជាតិស្តីពីជំនួយរដ្ឋបាលទៅវិញទៅមកក្នុងកិច្ចការគយ " ឬហៅកាត់ថា អនុសញ្ញា**យ៉ូហាន់ណឺស្បឺក** (Johannesburg Convention) នឹងផ្តល់ផលប្រយោជន៏ដល់កម្ពុជាក្នុងការចូលរួមក្នុងបណ្តាញសហប្រតិបត្តិការ និងជួយគ្នាទៅវិញទៅមកក្នុងកិច្ចការគយដូចមានចែងក្នុងចំណុចទី៥ខាងលើ ហើយក៏ជាដំណើរការក្នុងការចូលរួមជាបន្តបន្ទាប់ទៅក្នុងអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ពន្ធ័នឹងការគ្រប់គ្រង និងសម្រួលចរន្តពាណិជ្ជកម្មអន្តរជាតិព្រមទាំងបង្ហាញពីសកម្មភាពជាក់ស្តែងក្នុងដំណើរការសមាហរណកម្មកម្ពុជាទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក។

៧-ដោយយល់ពីផលប្រយោជន៏ និងតម្រូវការចាំបាច់ខាងលើរាជរដ្ឋាភិបាលបានផ្តល់សិទ្ធិប្រទាន់លេខ០៦ សប្រទ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៤ ជូនឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ដើម្បីចុះហត្ថលេខាលើ "អនុសញ្ញាអន្តរជាតិស្តីពីជំនួយរដ្ឋបាលទៅវិញទៅមកក្នុងកិច្ចការគយ " នៅក្នុងឱកាសដែលឯកឧត្តមដឹកនាំ-គណៈប្រតិភូគយកម្ពុជាទៅចូលរួមសន្និបាតប្រចាំឆ្នាំលើកទី ១០៣/១០៤ របស់អង្គការគយពិភពលោក ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៤-២៦ ខែមិថុនា ឆ្នាំ២០០៤ នៅទីក្រុង ប្រ៊ុចសែល។

៨-យោងតាមមាត្រា៤៦ និងមាត្រា៥១ នៃ "អនុសញ្ញាអន្តរជាតិស្តីពីជំនួយរដ្ឋបាលទៅវិញទៅមកក្នុងកិច្ចការគយ " សម្រាប់ប្រទេសកម្ពុជា អនុសញ្ញានេះនឹងចូលជាធរមានក្រោយរយៈពេល៣ខែបន្ទាប់ពីលិខិតូបករណ៍សច្ចាប័នរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួល និងតម្កល់ដោយអគ្គលេខាធិការនៃអង្គការគយពិភពលោក ។

អាស្រ័យដូចបានជម្រាបជូន និងទូលថ្វាយខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការជួយគ្នាទៅវិញទៅមកក្នុងកិច្ចការរដ្ឋបាលគយនេះ ដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ០៧. សប្រក

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ: ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម ប៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ដើម្បីចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីពីការជួយគ្នាទៅវិញទៅមកផ្នែករដ្ឋបាលគយ (International Convention on Mutual Administrative Assistance in Customs Matters) នៅក្នុងកិច្ចប្រជុំលើកទី ១០៣/១០៤ របស់អង្គការគយពិភពលោកដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៤-២៦ ខែ មិថុនា ឆ្នាំ ២០០៤ នាទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្ស៊ិក ។

អាស្រ័យហេតុនេះ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូនបានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

រាជរដ្ឋាភិបាល

*Royal Government*

No. 06 D-F-P

Phnom Penh, March 09 2004

**DELEGATION OF FULL POWER**

The Royal Government of Cambodia delegates herewith full power to H.E. Pen Siman, Delegate of the Royal Government in charge of the Customs and Excise Department, to sign the *International Convention on Mutual Administrative Assistance in Customs Matters* which will take place during the 103rd/104th Council Sessions of the World Customs Organization held in Brussels, Belgium on 24-26 June 2004.

In witness whereof the undersigned, the Prime Minister of the Royal Government of Cambodia, with full power duly entrusted to him, has signed this delegation of full power.

HUN

Prime Minister

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# ជំនួយរដ្ឋបាលទៅវិញទៅមក
# ក្នុងកិច្ចការគយ

ប្រ៊ុចសែល ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៣

អង្គការគយពិភពលោក
Rue du Marche, 30, B-1210 Bruxelles, Belgique
Telephone : 30(0)2209 9211 Fax : 30(0)2 209 92 92
Http : //www.wcoomd.org

# មាតិកា


| | ទំព័រ |
|---|---|
| មុខ្ខកថា | ១ |
| ជំពូក ១ - និយមន័យ (មាត្រា១) | ២ |
| ជំពូក ២ - វិសាលភាពនៃអនុសញ្ញា (មាត្រា ២) | ៤ |
| ជំពូក ៣ - នីតិវិធី នៃជំនួយជាទូទៅ | |
| មាត្រា ៣ : ទំនាក់ទំនងនៃសំណើ | ៥ |
| មាត្រា ៤ : ការផ្តល់ជំនួយជាបន្ទាន់ | ៦ |
| ជំពូក ៤ - ពត៌មាន | |
| មាត្រា ៥ : ពត៌មានសំរាប់ការអនុវត្ត និងប្រតិបត្តិការច្បាប់គយ | ៦ |
| មាត្រា ៦ : ពត៌មានទាក់ទងនឹងបទល្មើសគយ | ៧ |
| មាត្រា ៧ : ពត៌មានសំរាប់ការគិតពន្ធគយ និងអាករផ្សេងទៀត លើការនាំចូល និងនាំចេញ | ៧ |
| មាត្រា ៨ : ប្រភេទពត៌មានពិសេស | ៨ |
| មាត្រា ៩ : ការផ្លាស់ប្តូរពត៌មានដោយស្វ័យប្រវត្តិកម្ម | |
| មាត្រា ១០ : ការផ្លាស់ប្តូរជាមុននៃពត៌មាន | ៨ |
| ជំពូក ៥ - ប្រភេទពិសេសនៃជំនួយ | ១០ |
| មាត្រា ១១ : ការឃ្លាំមើល | ១០ |
| មាត្រា ១២ : ការត្រួតពិនិត្យការប្រគល់ទំនិញ | ១០ |
| មាត្រា ១៣ : ការជូនដំណឹង | ១១ |
| មាត្រា ១៤ : ការទារបាននូវទារពឹងរបស់គយ | ១១ |
| មាត្រា ១៥ : អ្នកជំនាញការ និង សាក្សី | |
| មាត្រា ១៦ : វត្តមាននៃមន្ត្រីគយនៅក្នុងដែនដីនៃភាគីហត្ថលេខី មួយផ្សេងទៀត | ១២ |
| មាត្រា ១៧ : វត្តមាននៃមន្ត្រីគយនៃរដ្ឋបាលស្នើសុំចំពោះ ការអញ្ជើញនៃរដ្ឋបាលទទួលសំណើ | ១២ |
| មាត្រា ១៨ : ការរៀបចំទស្សនះកិច្ចរបស់មន្ត្រីគយ | ១២ |

ជំពូក ៦ - សហប្រតិបត្តិការឆ្លងដែន

មាត្រា ១៩ : បទបញ្ញត្តិទូទៅ ១៣

មាត្រា ២០ : ការប្រដេញប្រតិត ១៣

មាត្រា ២១ : ការឃ្លាំមើលឆ្លងដែន ១៤

មាត្រា ២២ : ប្តូរការស៊ើបអង្កេត ១៤

មាត្រា ២៣ : ការត្រួតពិនិត្យរួមគ្នា និងក្រុមស៊ើបអង្កេត ១៥

ជំពូក ៧ - ការប្រើប្រាស់ ការរក្សាការសំងាត់និងការការពារពត៌មាន ១៥

មាត្រា ២៤ : ការប្រើពត៌មាន ១៥

មាត្រា ២៥ : ភាពសំងាត់ និងការការពារពត៌មាន ១៦

មាត្រា ២៦ : ការការពារទិន្នន័យផ្ទាល់ខ្លួន ១៣

ជំពូក ៨ - មជ្ឈការនៃពត៌មាន ១៧

មាត្រា ២៧ : គោលបំណងនៃមជ្ឈការ ១៨

មាត្រា ២៨ : ពត៌មានមិនផ្ទាល់ខ្លួន ១៨

មាត្រា ២៩ : ពត៌មាន ស្តីពី នីតិបុគ្គល និងរូបវ័ន្តបុគ្គល ១៨

មាត្រា ៣០ : ពត៌មានផ្សេងៗ ២០

មាត្រា ៣១ : មជ្ឈមណ្ឌលប្រព័ន្ធព័តមានស្វ័យប្រវត្តិកម្ម ២០

មាត្រា ៣២ : ការគ្រប់គ្រងមជ្ឈមណ្ឌលប្រព័ន្ធពត៌មាន
ស្វ័យប្រវត្តិកម្ម ២១

ជំពូក ៩ - សន្តិសុខ នៃមជ្ឈមណ្ឌលប្រព័ន្ធព័តមានស្វ័យប្រវត្តិកម្ម ២២

មាត្រា ៣៣ : ការទទួលខុសត្រូវលើវិធានការសន្តិសុខ ២២

មាត្រា ៣៤ : ការអនុវត្តវិធានការសន្តិសុខ ២៣

ជំពូក ១០ - ការការពារនូវមជ្ឈមណ្ឌលប្រព័ន្ធព័តមានស្វ័យប្រវត្តិកម្មក ២៣

មាត្រា ៣៥ : ការបញ្ចូលពត៌មាន ២៣

មាត្រា ៣៦ : ការប្រើប្រាស់ពត៌មាន ២៣

មាត្រា ៣៧ : ការរក្សាទុកទិន្នន័យផ្ទាល់ខ្លួន ២៤

មាត្រា ៣៨ : ការចូលប្រើប្រាស់ ២៥

មាត្រា ៣៩ : ការកែសម្រួលព័ត៌មានមិនផ្ទាល់ខ្លួននៅក្នុងប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ២៦

មាត្រា ៤០ : ការកែសម្រួលព័ត៌មានផ្ទាល់ខ្លួននៅក្នុងប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ២៦

មាត្រា ៤១ : ការទទួលខុសត្រូវ ២៨

**ជំពូក ១១** - ការលើកលែង និងការត្រៀមបំរុង ២៨

មាត្រា ៤២ : ការលើកលែង ២៨

មាត្រា ៤៣ : ការត្រៀមបំរុង ២៩

**ជំពូក ១២** - ការចំណាយ (មាត្រា ៤៤) ២៩

**ជំពូក ១៣** - អវសានប្បញ្ញត្តិ ៣០

មាត្រា ៤៥ : ការគ្រប់គ្រងនៃអនុសញ្ញា ៣០

មាត្រា ៤៦ : ការចុះហត្ថលេខា សច្ចានុមតិ និងការចូលជាសមាជិក ៣២

មាត្រា ៤៧ :ដែនដីអនុវត្តន៍នៃអនុសញ្ញា ៣៣

មាត្រា ៤៨ : អនុវត្តន៍នៃអនុសញ្ញា ៣៣

មាត្រា ៤៩ : វិសោធនកម្មនៃអនុសញ្ញា ៣៤

មាត្រា ៥០ : ការដោះស្រាយវិវាទ ៣៤

មាត្រា ៥១ : ការចូលជាធរមាន ៣៥

មាត្រា ៥២ : ការជំទាស់ ៣៥

មាត្រា ៥៣ : ការតំកល់នៃអនុសញ្ញា ៣៥

មាត្រា ៥៤ : ការចុះបញ្ជី និងអត្ថបទយថាភូត ៣៥

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# ជំនួយរដ្ឋបាលទៅវិញទៅមក
# ក្នុងកិច្ចការគយ

## បុព្វកថា

- ភាគីហត្ថលេខីនៃអនុសញ្ញានេះ ត្រូវបានបង្កើតឡើងក្រោមការគាំទ្ររបស់ក្រុមប្រឹក្សាសហប្រតិបត្តិការគយដែលបច្ចុប្បន្នហៅថាអង្គការគយពិភពលោក។
- ដោយទទួលស្គាល់ថាសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងរដ្ឋបាលគយ គឺជាគោលបំណងដ៏ចំបងនៃអនុសញ្ញាដែលបង្កើតឡើងដោយក្រុមប្រឹក្សាសហប្រតិបត្តិការគយ។
- ដោយជឿជាក់ថាកិច្ចសហប្រតិបត្តិការកាន់តែមានប្រសិទ្ធិភាព រវាងរដ្ឋបាលគយអាចសំរេចបានជោគជ័យពីសុឆន្ទៈរបស់ភាគីហត្ថលេខី។
- ដោយយល់ឃើញអំពីសារៈសំខាន់នៃការវាយតំលៃពន្ធគយ និងអាករផ្សេងទៀតឱ្យបានត្រឹមត្រូវ និងការធានាអោយរដ្ឋបាលគយអនុវត្តច្បាប់បានត្រឹមត្រូវចំពោះការហាមឃាត់ ឬអាយ័តកម្ម ការរឹតត្បិត និងវិធានការត្រួតពិនិត្យលើទំនិញជាក់ស្តែង។
- ដោយយល់ឃើញថាបទល្មើសគយ គឺជាការធ្វើអោយអន្តរាយនិងខូចប្រយោជន៍ដល់សុវត្ថិភាពរបស់ភាគីហត្ថលេខី និងសេដ្ឋកិច្ច ពាណិជ្ជកម្ម សារពើពន្ធ សង្គម សុខុមាលភាពសាធារណៈ និង វប្បធម៌របស់ពួកគេ។
- ដោយយល់ឃើញថាមានការគំរាមកំហែងពីឧក្រិដ្ឋកម្មឆ្លងដែន និងក្រុមភេរវករដែលមានប្រភពធនធានដ៏ធំធេង និងតំរូវឱ្យមានការប្រយុទ្ធប្រឆាំងយ៉ាងមានប្រសិទ្ធិភាព។
- ដោយទទួលស្គាល់ថា មានការព្រួយបារម្ភជាសកលកាន់តែកើនឡើងចំពោះសន្តិសុខ និងការសម្របសម្រួលនៃខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិនិង

សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាសហប្រតិបត្តិការគយ ខែមិថុនា ឆ្នាំ ២០០២ ចំពោះផលប៉ះពាល់ទាំងនោះ។

- ដោយទទួលស្គាល់ពីសារៈសំខាន់ នៃការធ្វើឱ្យសំរេចបាននូវតុល្យភាពរវាងការប្រព្រឹត្តស្របច្បាប់ និងការសម្របសម្រួល ដើម្បីជានាដល់លំហូរដោយសេរីនៃពាណិជ្ជកម្មស្របច្បាប់ និងដើម្បីឆ្លើយតបនូវតំរូវការរបស់រដ្ឋាភិបាលក្នុងការការពារផលប្រយោជន៍សង្គម និងចំណូលជាតិ។
- ដោយមានជំនឿថាពាណិជ្ជកម្មអន្តរជាតិត្រូវមានការសម្របសម្រួលដោយការអនុវត្តបច្ចេកទេសត្រួតពិនិត្យទំនើប ដូចជាការគ្រប់គ្រងហានិភ័យដោយរដ្ឋបាលគយ។
- ដោយយល់ឃើញថាការផ្លាស់ប្តូរព័ត៌មានជាអន្តរជាតិ គឺជាផ្នែកមួយដ៏សំខាន់នៃការគ្រប់គ្រងហានិភ័យដ៏មានប្រសិទ្ធិភាព ហើយការផ្លាស់ប្តូរព័ត៌មាននេះ គួរតែឈរលើមូលដ្ឋាននៃគតិយុត្តិច្បាស់លាស់។
- ដោយយល់ឃើញថាអន្តរជាតិ ស្តីពី ជំនួយរដ្ឋបាលទៅវិញទៅមកសំរាប់ការទប់ស្កាត់ការ ការស៊ើបអង្កេត និងការបង្ក្រាបបទល្មើសគយ ដែលអនុម័តនៅទីក្រុងណៃរ៉ូប៊ីកាលពីថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ១៩៧៧ ក្រោមជំនួយគាំទ្ររបស់ក្រុមប្រឹក្សាសហប្រតិបត្តិការគយ ដែលបានដាក់ចេញនូវក្របខ័ណ្ឌការងារដើម្បីជួយសម្រួលដល់ជំនួយរដ្ឋបាលទៅវិញទៅមកក្នុងកិច្ចការគយ។
- ដោយយល់ឃើញថាអនុសញ្ញានៃអង្គការសហប្រជាជាតិ ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលបានអនុម័តនៅទីក្រុងញូយកនាថ្ងៃទី១៥ ខែ វិច្ឆកា ឆ្នាំ ២០០០ និងសន្និសិទដែលបានចុះហត្ថលេខាដោយអ្នកនយោបាយជាន់ខ្ពស់នៅទីក្រុងប៉ាឡេរ៉ម៉ូកាលពីថ្ងៃទី ១២-១៥ ខែ ធ្នូ ឆ្នាំ ២០០០ ដែលដាក់ចេញនូវគំរោងការងារសំរាប់ការជួយគ្នាទៅវិញទៅមកជាអន្តរជាតិទាក់ទងនឹងឧក្រិដ្ឋកម្មដើម្បីទប់ស្កាត់និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋឆ្លងដែនដែលមានការចាត់តាំង។
- យោងតាមអនុសញ្ញាអន្តរជាតិស្តីពីការហាមឃាត់ ការរឹតត្បិត និងវិធានការត្រួតពិនិត្យលើទំនិញជាក់ស្តែងមួយចំនួន។
- យោងសេចក្តីប្រកាសរួមជាសកលរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្សនៅឆ្នាំ១៩៤៨។

បានយល់ព្រមដូចតទៅ ៖

## ជំពូក ១
## និយមន័យ
### មាត្រា ១

គោលបំណងនៃអនុសញ្ញានេះ ៖

(ក). "គណៈកម្មាធិការរដ្ឋបាល" មានន័យថា គណៈកម្មាធិការដែលទទួលខុសត្រូវលើការគ្រប់គ្រងអនុសញ្ញានេះ ដូចមានចែងក្នុងមាត្រា ៤៥។

(ខ). "ក្រុមប្រឹក្សា" មានន័យថា របទានសម្ព័ន្ធចាត់តាំងនៃអនុសញ្ញានេះ ដែលបានបង្កើតឡើងដោយក្រុមប្រឹក្សាសហប្រតិបត្តិការគយ ធ្វើនៅទីក្រុងប្រ៊ុចសែលថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៥០ ហើយបានចូលជាធរនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥២។

(គ). "មន្ត្រីក្រុមប្រឹក្សា" មានន័យថា មន្ត្រីទូទៅឬនិយោជិតនៃក្រុមប្រឹក្សា និងបុគ្គលផ្សេងទៀត ដែលតែងតាំងដោយអគ្គលេខាធិការ ដើម្បីបំពេញមុខងារតាមគោលបំណងនៃអនុសញ្ញានេះ។

(ឃ). "សហប្រតិបត្តិការឆ្លងដែន" មានន័យថាសហប្រតិបត្តិការរវាងរដ្ឋបាលគយនៃប្រទេសហត្ថលេខីឆ្លងកាត់ព្រំដែនរបស់គេរៀងៗខ្លួន។

(ង). "រដ្ឋបាលគយ" មានន័យថា អាជ្ញាធរគយ និងអាជ្ញាធរផ្សេងទៀតនៃប្រទេសហត្ថលេខីដែលទទួលសិទ្ធិស្របតាមច្បាប់ជាតិនិងត្រូវបានតែងតាំងដោយប្រទេសហត្ថលេខីដើម្បីអនុវត្តនៅក្នុងបទបញ្ញត្តិនៃអនុសញ្ញានេះ។

(ច). "ការតឹងទារប្រាក់ពន្ធគយ" មានន័យថា ចំនួនទឹកប្រាក់ពន្ធគយដែលមិនអាចប្រមូលបានក្នុងប្រទេសដែលជាភាគីហត្ថលេខីណាមួយ។

(ឆ). "ពន្ធគយ" មានន័យថា ពន្ធគយនាំចូលនាំចេញ អាករ កម្រៃ ឬការបង់ប្រាក់ផ្សេងទៀត ដែលហួតយកនៅក្នុងដែនដីនៃភាគីហត្ថលេខីក្នុងការអនុវត្តច្បាប់គយ ប៉ុន្តែមិនរាប់បញ្ចូលកម្រៃ និងការបង់ប្រាក់ផ្សេងទៀតចំពោះផ្តល់សេវាទេ។

(ជ). "ច្បាប់គយ" មានន័យថា ច្បាប់ និងបទបញ្ញត្តិរដ្ឋបាលទាំងឡាយដែលអាចអនុវត្តឬបង្ខិតឱ្យគោរពតាមដោយរដ្ឋបាលគយនៃភាគីហត្ថលេខីពាក់ព័ន្ធទៅនឹងការ

នាំចូលនាំចេញ ការផ្ទេរនាវា ការឆ្លងកាត់ ការស្តុកទុក និងចរាចរ នៃទំនិញ ដោយរួមបញ្ចូលទាំងបទបញ្ញត្តិរដ្ឋបាល ដែលទាក់ទងនឹងវិធាននៃការហាមឃាត់ ការរឹតត្បិតនិងការត្រួតពិនិត្យ និងដើម្បីប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់។

(ឈ). "បទល្មើសគយ" មានន័យថា ការរំលោភ ឬការព្យាយាមរំលោភច្បាប់គយ របស់ប្រទេសជាភាគីហត្ថលេខី។

(ញ). "សហភាពគយឬសេដ្ឋកិច្ច" មានន័យថា សហភាពដែលបង្កើតឡើង និងមាន សមាសភាពជាសមាជិកដែលមានសមត្ថកិច្ចអនុម័តច្បាប់របស់ខ្លួន ដែលបានចង សមាជិកភាពទាំងនេះនៅក្នុងអនុសញ្ញានេះ និងមានសមត្ថកិច្ចសំរេចដោយអនុ លោមទៅតាមនីតិវិធីផ្ទៃក្នុង ដើម្បីចុះហត្ថលេខាឱ្យសច្ចាប័ន ឬអនុម័តយល់ព្រម លើអនុសញ្ញានេះ។

(ដ). "គណៈកម្មាធិការអនុវត្តច្បាប់" មានន័យថា គណៈកម្មាធិការអនុវត្តច្បាប់នៃ ក្រុមប្រឹក្សា។

(ឋ). "ព័ត៌មាន" មានន័យថា ទិន្នន័យទោះបីជាមានកែច្នៃឬវិភាគ និងឯកសារ របាយការណ៍ និងការងារទំនាក់ទំនងផ្សេងទៀត ក្នុងទម្រង់ណាក៏ដោយរួម បញ្ចូលទាំងអេឡិចត្រូនិក ឬច្បាប់ថតចម្លងដែលមានការបញ្ជាក់ថាត្រឹមត្រូវតាម ច្បាប់ដើមឬយថាភូត។

(ឌ). "ខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ" មានន័យថា ដំណើរការទាំងឡាយណា ដែលពាក់ព័ន្ធក្នុងចរាចរទំនិញឆ្លងកាត់ព្រំដែន ពីទីកន្លែងដើមទីរហូតដល់គម្យ ដ្ឋាន។

(ណ). "មន្ត្រី" មានន័យថា មន្ត្រីគយឬភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត តែងតាំងដោយ រដ្ឋបាលគយ។

(ត). "បុគ្គល" មានន័យថា រូបវន្ត ឬនីតិបុគ្គល លើកលែងមានចែងនៅក្នុងច្បាប់ ផ្សេង។

(ថ). "ទិន្នន័យផ្ទាល់ខ្លួន" មានន័យថា ទិន្នន័យទាំងឡាយណាដែលពាក់ពន្ធ័នឹងការ កំណត់អត្តសញ្ញាណ ឬការអាចកំណត់អត្តសញ្ញាណពីរូបវន្តបុគ្គល។

(ទ). "សច្ចានុមតិ" រួមមាន ការទទួលស្គាល់ និងការយល់ព្រម។

(ធ). "រដ្ឋបាលស្នើសុំ" មានន័យថា រដ្ឋបាលគយដែលស្នើសុំឱ្យគេជួយ។

(ន). "រដ្ឋបាលទទួលសំណើ" មានន័យថា រដ្ឋបាលគយដែលទទួលការស្នើសុំឱ្យជួយ។

(ប). "ភាគីហត្ថលេខីស្នើសុំ" មានន័យថា ភាគីហត្ថលេខីដែលរដ្ឋបាលគយរបស់ខ្លួនស្នើសុំឱ្យគេជួយ។

(ផ). "ភាគីហត្ថលេខីទទួលសំណើ" មានន័យថា ភាគីហតលេខីដែលរដ្ឋបាលគយរបស់ខ្លួនទទួលនូវការស្នើសុំឱ្យផ្តល់ជំនួយ។

(ព). "អគ្គលេខាធិការ" មានន័យថា អគ្គលេខាធិការនៃក្រុមប្រឹក្សា។

## ជំពូក ២
## វិសាលភាពនៃអនុសញ្ញា
### មាត្រា ២

១. តាមរយៈរដ្ឋបាលគយរបស់ខ្លួន ភាគីហត្ថលេខី ត្រូវផ្តល់ជំនួយឱ្យគ្នាទៅវិញទៅមកក្រោមលក្ខខណ្ឌដែលមានចែងនៅក្នុងអនុសញ្ញានេះ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវនូវច្បាប់គយក្នុងការទប់ស្កាត់ ស៊ើបអង្កេត និងប្រយុទ្ធប្រឆាំងបទល្មើសគយ និងដើម្បីធានាសន្តិសុខនៃខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ។

២. សកម្មភាពទាំងឡាយណាដែលបានអនុវត្តក្រោមអនុសញ្ញានេះ ដោយភាគីហត្ថលេខី ត្រូវអនុលោមតាមបទបញ្ញត្តិច្បាប់និងរដ្ឋបាល រួមជាមួយនឹងសមត្ថកិច្ចរដ្ឋបាលគយដែលមានកំរិត និងប្រភពធនធានរបស់ខ្លួនដែលមាន។

៣. យោងតាមមាត្រា ១(ង) ភាគីហេលេខីនីមួយៗ ត្រូវជូនដំណឹងដល់អគ្គលេខាធិការនៃអាជ្ញាធរដែលទទួលសិទ្ធពីច្បាប់ជាតិ និងចាត់តាំងដោយភាគីហត្ថលេខី ដើម្បីអនុវត្តនូវបទបញ្ញត្តិនៃអនុសញ្ញានេះ។ អគ្គលេខាធិការ ត្រូវធ្វើការទាក់ទងទៅភាគីហត្ថលេខីផ្សេងទៀតអំពីព័ត៌មាននេះ និងការប្រែប្រួលថ្មីៗ ។

៤. អនុសញ្ញានេះ គ្របដណ្តប់តែលើការជួយគ្នាទៅវិញទៅមកផ្នែករដ្ឋបាលរវាងភាគីហត្ថលេខីតែប៉ុណ្ណោះ គឺគ្មានបំណងធ្វើឱ្យប៉ះពាល់ដល់កិច្ចព្រមព្រៀងជំនួយទៅវិញទៅមកផ្នែកច្បាប់រវាងភាគីហត្ថលេខីនោះឡើយ។ ប្រសិនបើ ការផ្តល់ជំនួយទៅវិញទៅមក ត្រូវបានផ្តល់ដោយអាជ្ញាធរផ្សេងនៃភាគីហត្ថលេខីទទួល

សំណើរដ្ឋបាលទទួលសំណើ ត្រូវបញ្ជាក់អំពីអាជ្ញាធរទាំងនោះនិងប្រាប់ឱ្យដឹងពីកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ឬការរៀបចំដែលអាចអនុវត្តបាន។

៩. បទបញ្ញត្តិនៃអនុសញ្ញានេះមិនធ្វើឱ្យប៉ះពាល់ដល់ផ្នែកណាមួយនៃសិទ្ធិបុគ្គលដែលជាឧបសគ្គនៃការប្រតិបត្តិនៃការស្នើសុំជំនួយនេះទេ។

## ជំពូក ៣

## នីតិវិធីជំនួយទុះទៅ

### មាត្រា ៣

### ទំនាក់ទំនងនៃសំណើ

១. សំណើសុំជំនួយក្រោមអនុសញ្ញានេះ ត្រូវធ្វើការទំនាក់ទំនងដោយផ្ទាល់រវាងរដ្ឋបាលគយដែលពាក់ព័ន្ធ។ រដ្ឋបាលគយនីមួយៗ ត្រូវតែងតាំងមន្ត្រីទំនាក់ទំនងសម្រាប់កិច្ចការនេះហើយត្រូវផ្តល់ព័ត៌មានពិស្តារជូនដល់អគ្គលេខាធិការ។ អគ្គលេខាធិការ ត្រូវធ្វើការទាក់ទងអំពីព័ត៌មានទាំងនេះ និងការប្រែប្រួលថ្មីៗទៅរដ្ឋបាលគយផ្សេងទៀត។

២. សំណើសុំជំនួយក្រោមអនុសញ្ញានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយអេឡិចត្រូនិក និងអាចភ្ជាប់ជាមួយនូវព័ត៌មានចាំបាច់ផ្សេងៗទៀតក្នុងគោលបំណងឆ្លើយតបទៅនឹងសំណើនោះ។ រដ្ឋបាលទទួលសំណើ អាចទាមទារការបញ្ជាក់ជាលាយលក្ខណ៍អក្សរនៃសំណើដោយអេឡិចត្រូនិក។ ក្នុងកាលៈទេសៈចាំបាច់ អាចធ្វើការស្នើសុំដោយផ្ទាល់មាត់។ សំណើទាំងនោះ អាចធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរឬតាមប្រព័ន្ធអេឡិចត្រូនិកអោយ បានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើបានប្រសិនបើអាចទទួលយកបានពីសំណាក់រដ្ឋបាលទទួលសំណើ និងរដ្ឋបាលធ្វើការស្នើសុំ ។

៣. សំណើ ត្រូវធ្វើឡើងជាភាសាដែលអាចទទួលយកបានដោយរដ្ឋបាលគយពាក់ព័ន្ធ។ ឯកសារយោងភ្ជាប់នឹងសំណើ ត្រូវបកប្រែទៅជាភាសាដែលអាចទទួលយកបានទៅវិញទៅមក បើសិនជាមានការចាំបាច់។ រដ្ឋបាលទទួលសំណើ គួរទទួលយក

នូវសំណើសុំជំនួយនិងឯកសារយោងទាំងឡាយ ជាភាសាមួយក្នុងចំណោមភាសាផ្លូវការដែលបានកំណត់ដោយក្រុមប្រឹក្សា។

៤. សំណើ ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមកថាខ័ណ្ឌទី ២ នៃមាត្រានេះ ត្រូវបញ្ចូលនូវចំណុចពិស្តារដូចខាងក្រោម :

(ក). ឈ្មោះរដ្ឋបាលស្នើសុំ

(ខ). បញ្ហាសំខាន់ ប្រភេទនៃជំនួយដែលបានស្នើឡើង និងមូលហេតុនៃការស្នើសុំ។

(គ). ការបកស្រាយសង្ខេបនៃសំណុំរឿង ក្រោមការត្រួតពិនិត្យឡើងវិញ និងបទបញ្ញត្តិច្បាប់និងរដ្ឋបាលដែលអនុវត្ត។

(ឃ). ឈ្មោះ និងអាសយដ្ឋាន នៃបុគ្គលដែលពាក់ព័ន្ធនឹងសំណើប្រសិនស្គាល់។

(ង). ឯកសារយោង ស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រា ៤២ ប្រសិនបើអាចអនុវត្តបាន។

(ច). ការផ្ទៀងផ្ទាត់ ស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រា ៧ ។

៥. នៅពេលដែលរដ្ឋបាលស្នើសុំ ធ្វើតាមនីតិវិធីឬវិធីសាស្ត្រច្បាស់លាស់រដ្ឋបាលទទួលសំណើ ត្រូវអនុវត្តតាមសំណើអនុលោមតាមបទបញ្ញត្តិច្បាប់ជាតិ និងរដ្ឋបាល។

## មាត្រា ៤
## ការផ្តល់ជំនួយបន្ទាន់

ក្នុងករណីពាក់ព័ន្ធដល់ការខូចខាតយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច សុខមាលភាពសាធារណៈ សន្តិសុខសាធារណៈ ដោយរាប់បញ្ចូលទាំងសន្តិសុខនៃខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ ឬផលប្រយោជន៍សំខាន់ៗផ្សេងទៀតរបស់ភាគីហត្ថលេខីណាមួយរដ្ឋបាលគយនៃភាគីហត្ថលេខី ត្រូវផ្តល់ជំនួយតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ដោយមិនបង្អែរបង្អង់យូរឡើយតាមលទ្ធភាពដែលអាចធ្វើបាន។

## ជំពូក ៤
## ព័ត៌មាន

### មាត្រា ៥
### ព័ត៌មានអនុវត្តន៍និងការប្រតិបត្តិច្បាប់គយ

រដ្ឋបាលគយទាំងអស់ ត្រូវផ្តល់ជូនគ្នាទៅវិញទៅមកនូវព័ត៌មាន ទោះបីតាមរយៈការស្នើសុំឬគំនិតផ្តួចផ្តើមផ្ទាល់ខ្លួនក៏ដោយ ដើម្បីធានាដល់ការអនុវត្តច្បាប់គយនិងការទប់ស្កាត់ ស៊ើបអង្កេត និង ប្រយុទ្ធប្រឆាំងបទល្មើសគយ និងធានាអោយបាននូវសន្តិសុខ នៃខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ។ ព័ត៌មានទាំងនោះ រួមមានៈ

(ក). បច្ចេកទេសអនុវត្តច្បាប់ថ្មី ដែលបានបង្ហាញឱ្យឃើញអំពីភាពស័ក្តិសិទ្ធិរបស់ខ្លួន។

(ខ). និន្នាការ មធ្យោបាយ ឬវិធីសាស្ត្រថ្មី នៃការប្រព្រឹត្តបទល្មើសគយ

(គ). ទំនិញដែលគេស្គាល់ថាជាកម្មវត្ថុនៃបទល្មើសគយ ព្រមទាំងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន និងវិធីសាស្ត្រស្តុកទុកទំនិញពាក់ព័ន្ធទាំងនោះ។

(ឃ). បុគ្គលទាំងឡាយណាដែលគេស្គាល់ថាបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាកំពុងប្រព្រឹត្តបទល្មើសគយ។

(ង). ទិន្នន័យទាំងឡាយណាដែលអាចជួយដល់រដ្ឋបាលគយ អោយធ្វើការវាយតម្លៃហានិភ័យដើម្បីបំរើដល់គោលបំណងនៃការត្រួតពិនិត្យនិងការសម្របសម្រួល ។

### មាត្រា ៦
### ព័ត៌មានពាក់ព័ន្ធនឹងបទល្មើសគយ

រដ្ឋបាលគយនៃភាគីហត្ថលេខី ត្រូវផ្តល់រដ្ឋបាលគយនៃភាគីហត្ថលេខីផ្សេងទៀតដែលពាក់ព័ន្ធតាមសំណើ ឬគំនិតផ្តួចផ្តើមផ្ទាល់ខ្លួននូវព័ត៌មានអំពីសកម្មភាព ផែនការការងារដែលកំពុងដំណើរការឬបានបញ្ចប់ ដែលផ្តល់ជាមូលដ្ឋានសមហេតុផលដែលគួរអោយជឿជាក់បានថា បានប្រព្រឹត្ត ឬនឹងប្រព្រឹត្តបទល្មើសគយនៅក្នុងដែនដីរបស់ភាគីពាក់ព័ន្ធ។

## មាត្រា ៧
## ព័ត៌មានសំរាប់ការគិតពន្ធ និងអាករ នាំចូលឬនាំចេញ

១. តាមសំណើដើម្បីគាំទ្រដល់ការអនុវត្តច្បាប់គយ ឬទប់ស្កាត់នូវការក្លែងបន្លំគយ ហើយប្រសិនបើមិនខូចប្រយោជន៍ដូចមានចែងក្នុងមាត្រា ៤២ រដ្ឋបាលទទួលសំណើ ត្រូវផ្តល់ព័ត៌មានដើម្បីជួយដល់រដ្ឋបាលស្នើសុំ អំពីមានហេតុផលក្នុងការសង្ស័យការពិតឬភាពត្រឹមត្រូវនៃប្រតិវេទន៍មួយ ។

២. ការស្នើសុំ ត្រូវបញ្ជាក់អំពីនីតិវិធីនានាដែលរដ្ឋបាលស្នើសុំ បានទទួលយកឬប៉ុនប៉ងធ្វើការផ្ទៀងផ្ទាត់ និងពីព័ត៌មានច្បាស់លាស់អំពីការស្នើសុំនោះ ។

## មាត្រា ៨
## ប្រភេទពិសេសនៃព័ត៌មាន

តាមសំណើ រដ្ឋបាលទទួលសំណើ ត្រូវផ្តល់ជូនរដ្ឋបាលស្នើសុំដែលមានការសង្ស័យអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានទទួលទាក់ទងនឹងការងារគយរបស់ខ្លួន គឺព័ត៌មានដែលជាប់ទាក់ទងនឹង:

(ក). ថាតើទំនិញដែលបាននាំចូលក្នុងដែនដីរបស់ភាគីហត្ថលេខីស្នើសុំ ហើយដែលបាននាំចេញពីដែនដីភាគីហត្ថលេខីទទួលសំណើស្របច្បាប់ដែរឬទេ។

(ខ). ថាតើទំនិញដែលបាននាំចេញពីដែនដីភាគីហត្ថលេខីស្នើសុំ បាននាំចូលក្នុងដែនដីរបស់ភាគីហត្ថលេខីទទួលសំណើស្របច្បាប់ដែរទេ និងនីតិវិធីដែរឬទេ ប្រសិនមាន។

## មាត្រា ៩
## ការផ្លាស់ប្តូរជាស្វ័យប្រវត្តិនៃព័ត៌មាន

តាមកិច្ចព្រមព្រៀងទៅវិញទៅមកស្របតាមកថាខណ្ឌទី២ នៃមាត្រា ៤៨ ភាគីហត្ថលេខីទាំងអស់ អាចផ្លាស់ប្តូរព័ត៌មានណាមួយដែលមានចែងក្នុងអនុសញ្ញានេះទៅតាមប្រព័ន្ធស្វ័យប្រវត្តិ។

## មាត្រា ១០
## ការផ្លាស់ប្តូរជាមុននៃព័ត៌មាន

១. តាមកិច្ចព្រមព្រៀងទៅវិញទៅមក អនុលោមតាមកថាខ័ណ្ឌទី២ នៃមាត្រា ៤៨ ភាគីហត្ថលេខីទាំងអស់ អាចផ្លាស់ប្តូរព័ត៌មានជាក់លាក់ជាមុន អំពីការមកដល់នៃទំនិញចូលក្នុងដែនដីរៀងៗ ខ្លួនជាពិសេសដើម្បីធានាឱ្យមានសន្តិសុខនៃខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ ។

២. ព័ត៌មានទាំងនោះ តាមលទ្ធភាពដែលអាចធ្វើទៅបាន ត្រូវមានសមាសធាតុទិន្នន័យ ដូចតទៅ ៖

i. អ្នកផ្ញើទំនិញ/លេខកូដ ឬអ្នកនាំចេញ/លេខកូដ
ii. យថាប្រភេទទំនិញ ឬលេខកូដតារាងពន្ធគយ
iii. លេខកូដ UNDG (លេខកូដទំនិញគ្រោះថ្នាក់)
iv. ប្រភេទនៃការសំគាល់ការវេចខ្ចប់
v. ចំនួនកូលី (ចំនួនកញ្ចប់)
vi. ខ្នាត ឯកតា រង្វាស់
vii. ទម្ងន់ដុល/សរុប
viii. ចំនួនទឹកប្រាក់សរុបក្នុងវិក័យប័ត្រ
ix. លេខកូដរូបិយប័ណ្ណ
x. ទីកន្លែងផ្ទុក ឬលេខកូដទីកន្លែងផ្ទុក
xi. អត្តសញ្ញាណ ឬឈ្មោះមធ្យោបាយដឹកជញ្ជូន
xii. លេខសំគាល់គ្រឿងចក្រ-បរិក្ខារ
xiii. ទំហំគ្រឿងចក្រ បរិក្ខារ និង អត្តសញ្ញាណប្រភេទ
xiv. លេខត្រា (សៀល)
xv. អត្តសញ្ញាណនៃមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែនរបស់ដែនដីនៃភាគីហត្ថលេខា ឬ លេខកូដ ។
xvi. សញ្ជាតិរបស់មធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃដែនដីនៃភាគីហត្ថលេខា ឬ លេខកូដ ។
xvii. លេខយោងរបស់មធ្យោបាយដឹកជញ្ជូន

xviii. វិធីសាស្ត្រនៃការទូទាត់បន្ទុកដឹកជញ្ជូន ឬលេខកូដ

xix. ការិយាល័យគយមាត់ច្រកចេញ ឬលេខកូដ

xx. គំរាយផ្លូវក្នុងប្រទេស ឬលេខកូដ

xxi. កំពង់ផែទីមួយនៃការមកដល់ ឬលេខកូដ

xxii. កាលបរិច្ឆេទ និង ពេលវេលានៃការមកដល់កំពង់ផែទីមួយក្នុងដែនដីនៃភាគីហត្ថលេខី ឬលេខកូដ

xxiii. អ្នកទទួលទំនិញ/លេខកូដ ឬ អ្នកនាំចូល/លេខកូដ

xxiv. ម្ចាស់ទំនិញ ឬលេខកូដ

xxv. គម្យដ្ឋានប្រគល់ទំនិញ

xxvi. ភ្នាក់ងារ ឬលេខកូដ

xxvii. លេខយោងទំនិញតែមួយ

៣. គណៈកម្មាធិការរដ្ឋបាលត្រូវមានសិទ្ធិធ្វើការកែប្រែបញ្ជីដោយយោងតាមកថាខណ្ឌទី ២ នៃមាត្រានេះ។

## ជំពូក ៥
## ប្រភេទពិសេសនៃជំនួយ

### មាត្រា ១១
### ការឃ្លាំមើល

១. តាមការស្នើសុំ រដ្ឋបាលទទួលសំណើ តាមលទ្ធភាពដែលអាចធ្វើទៅបាន ត្រូវថែរក្សាការឃ្លាំមើលទៅអោយរដ្ឋបាលស្នើសុំនូវព័ត៌មានដូចខាងក្រោម ស្តីពី :

(ក). ទំនិញកំពុងដឹកជញ្ជូន ឬកំពុងស្តុកទុក ដែលគេដឹងថាកំពុងប្រើប្រាស់ ឬបានសង្ស័យថាកំពុងប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសគយនៅក្នុងដែនដីនៃភាគីហត្ថលេខីស្នើសុំ។

(ខ). មធ្យោបាយដឹកជញ្ជូន ដែលគេដឹងថាកំពុងប្រើប្រាស់ ឬបានសង្ស័យថាពីការកំពុងប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសគយនៅក្នុងដែនដី នៃភាគីហត្ថលេខីស្នើសុំ ។

(គ). ទីតាំងអាជីវកម្ម ដែលគេដឹងថាកំពុងប្រើប្រាស់ ឬបានសង្ស័យថាពីការកំពុងប្រើប្រាស់ទាក់ទងនឹងកម្រៃជើងសារដើម្បីប្រព្រឹត្តបទល្មើសគយនៅក្នុងដែនដីនៃភាគីហត្ថលេខីស្នើសុំ។

(ឃ). បុគ្គលទាំងឡាយដែលបានប្រព្រឹត្ត ឬសង្ស័យអាចនឹងប្រព្រឹត្តបទល្មើសគយនៅក្នុងដែនដីនៃភាគីហត្ថលេខីស្នើសុំ ជាពិសេសការចរាចរចូល ឬចេញពីដែនដីនៃភាគីហត្ថលេខីទទួលសំណើ ។

២. រដ្ឋបាលគយនៃភាគីហត្ថលេខមួយ អាចរក្សាការឃ្លាំមើលទាំងនេះដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ប្រសិនបើមានហេតុផលអាចជឿទុកចិត្តថាផែនការសកម្មភាពដែលកំពុងដំណើការ ឬបានបញ្ជាប់បង្ហាញថាមានបទល្មើសគយនៅក្នុងដែនដីនៃភាគីហត្ថលេខីមួយផ្សេងទៀត។

## មាត្រា. ១២

## ការត្រួតពិនិត្យការប្រគល់ទំនិញ

១. តាមកិច្ចព្រមព្រៀងទៅវិញទៅមកស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ៤៨ ភាគីហត្ថលេខីទាំងអស់ អាចអនុញ្ញាតឱ្យទំនិញមិនត្រឹមត្រូវស្របច្បាប់ឬទំនិញសង្ស័យចរាចរចេញ ឆ្លងកាត់ ឬចូលទៅក្នុងដែនដីរបស់គេក្រោមសមត្ថកិច្ច និងការត្រួតពិនិត្យពីរដ្ឋបាលគយក្នុងគោលបំណងស៊ើបអង្កេត និងប្រយុទ្ធប្រឆាំងបទល្មើសគយ ។

២. ប្រសិនបើកិច្ចដំណើការទាំងនោះមិនអាចអនុវត្តបាន ក្រោមការត្រួតពិនិត្យពីអាជ្ញាធរគយអាជ្ញាធរនោះត្រូវព្យាយាមចាប់ផ្តើមសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិផ្សេងទៀត ដែលមានសមត្ថកិច្ចឬត្រូវតែផ្ទេរករណីនោះទៅអោយពួកគេ។

## មាត្រា ១៣

## ការជូនដំណឹង

១. តាមការស្នើសុំ ប្រសិនបើមានការអនុញ្ញាតដែលយោងតាមច្បាប់ជាតិ រដ្ឋបាលទទួលសំណើ ត្រូវចាត់វិធានការចាំបាច់ជូនដំណឹងទៅអោយបុគ្គលដែលកំពុងរស់

ទៅនឹងមានលំនៅដ្ឋាននៅក្នុងដែនដីរបស់ខ្លួននូវការសំរេចចិត្តទាំងឡាយដែលធ្វើឡើងដោយរដ្ឋបាលស្នើសុំក្នុងការអនុវត្តច្បាប់គយពាក់ព័ន្ធទៅនឹងបុគ្គល ដែលចែងក្នុងកិច្ចព្រមព្រៀងនេះ ។

២. ការជូនដំណឹងទាំងនោះ ត្រូវធ្វើឡើងដោយយោងតាមនីតិវិធីទាំងឡាយអនុវត្តនៅក្នុងដែនដី នៃភាគីហត្ថលេខីទទួលសំណើសំរាប់ការសំរេចចិត្តថ្នាក់ជាតិប្រហាក់ប្រហែល។

## មាត្រា ១៤
## ការទារបាននូវតឹងទាររបស់គយ

១. តាមការស្នើសុំ រដ្ឋបាលគយទាំងឡាយ អាចខិតខំជួយគ្នាទៅវិញទៅមកតាមលទ្ធភាពពាក់ព័ន្ធទៅនឹងទារបានមកវិញនូវតឹងទាររបស់គយ។

២. កិច្ចព្រមព្រៀងពិស្តារ សំរាប់ការជួយក្នុងការទារបានមកវិញនូវតឹងទាររបស់គយត្រូវបានធ្វើឡើង រវាងភាគីហត្ថលេខីទាំងឡាយដែលពាក់ព័ន្ធដោយអនុលោមទៅតាមកថាខ័ណ្ឌទី ២ នៃមាត្រាទី ៤៨ ។

## មាត្រា ១៥
## អ្នកជំនាញការ និង សាក្សី

តាមការស្នើសុំ រដ្ឋបាលទទួលសំណើ អាចអនុញ្ញាតមន្ត្រីរបស់ខ្លួនមកបង្ហាញខ្លួននៅមុខតុលាការ ឬសាលាក្តីនៅក្នុងទឹកដីនៃភាគីហត្ថលេខីស្នើសុំជាអ្នកជំនាញការ ឬសាក្សីនៅក្នុងផ្នែកដែលពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់គយ។

## មាត្រា ១៦
## វត្តមានមន្ត្រីនៅក្នុងដែនដីនៃភាគីហត្ថលេខីមួយផ្សេងទៀត

តាមការស្នើសុំ មន្ត្រីដែលបានតែងតាំងពិសេសដោយរដ្ឋបាលស្នើសុំ ដោយមានការអនុញ្ញាតពីរដ្ឋបាលទទួលសំណើ និង ត្រូវគោរពតាមល័ក្ខខ័ណ្ឌទាំងឡាយដែលអាចលើកឡើងនៅពេលក្រោយ អាចអនុវត្តសំរាប់គោលបំណងនៃការស៊ើបអង្កេតលើបទល្មើសគយ :

(ក). នៅក្នុងការិយាល័យនៃរដ្ឋបាលទទួលសំណើ ត្រួតពិនិត្យមើលឯកសារ និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធទៅនឹងបទល្មើសគយ និងផ្តល់ឱ្យជាមួយនឹងឯកសារថតចំលង។

(ខ). ត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបសួរដោយរដ្ឋបាលទទួលសំណើ នៅក្នុងដែនដីនៃភាគីហត្ថលេខីទទួលសំណើដែលជាប់ទាក់ទងនឹងរដ្ឋបាលស្នើសុំ មន្ត្រីទាំងនោះត្រូវមានតួនាទីជាទីប្រឹក្សា។

## មាត្រា ១៧
## វត្តមានមន្ត្រីនៃរដ្ឋបាលស្នើសុំ តាមការអញ្ជើញនៃរដ្ឋបាលទទួលសំណើ

១. នៅពេលរដ្ឋបាលទទួលសំណើ ពិចារណាឃើញថា មានហេតុផលសមរម្យតម្រូវឱ្យមន្ត្រីនៃរដ្ឋបាលស្នើសុំ បង្ហាញមុខតាមសំណើនៅពេលត្រូវអនុវត្តវិធានការនៃការផ្តល់ជំនួយ វិធានការនេះ ត្រូវអញ្ជើញអោយចូលរួមដោយរដ្ឋបាលស្នើសុំយោងទៅតាមល័ក្ខខ័ណ្ឌដែលអាចធ្វើបញ្ជាក់ច្បាស់លាស់។

២. យោងតាមកិច្ចព្រមព្រៀងស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រា ៤៨ រដ្ឋបាលគយដែលពាក់ព័ន្ធ អាចពង្រីកតួនាទីមន្ត្រីទស្សនៈកិច្ចលើសពីតួនាទីជាទីប្រឹក្សា។

## មាត្រា ១៨
## ការរៀបចំការធ្វើទស្សនៈកិច្ចរបស់មន្ត្រី

១. ដោយមិនប៉ះពាល់ដល់មាត្រា ១៩, ២០, ២១, ២២ និង ២៣ នៅពេលដែលមន្ត្រីនៃភាគី ហត្ថលេខីមួយ មានវត្តមាននៅក្នុងដែនដីនៃភាគីហត្ថលេខីផ្សេងទៀត ស្របតាមល័ក្ខខ័ណ្ឌនៃអនុសញ្ញានេះ ពួកគេគ្រប់ពេលវេលាទាំងអស់ត្រូវមានមានលទ្ធភាពបង្ហាញនូវភស្តុតាង នៃអត្តសញ្ញាណប័ណ្ណផ្លូវការរបស់ពួកគេ និងឋានៈតួនាទីនៅក្នុងរដ្ឋបាលគយ និងឋានៈតួនាទីជាផ្លូវការដែលបានផ្តល់អោយនៅក្នុងដែនដីនៃរដ្ឋបាលទទួលសំណើ ដោយប្រើប្រាស់ភាសាដែលអាចទទួលយកបានដោយរដ្ឋបាលទទួលសំណើ។

២. ក្នុងពេលដែលស្ថិតនៅក្នុងទឹកដីនៃភាគីហត្ថលេខីផ្សេងទៀត តាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ មន្ត្រីទាំងនេះ ត្រូវតែទទួលខុសត្រូវនូវបទល្មើសទាំងឡាយដែលគេអាចប្រព្រឹត្ត និងទទួលបានការគាំពារដូចគ្នានឹងមន្ត្រីគយរបស់ខ្លួន ដូចមាននៅក្នុងច្បាប់ជាតិរបស់ភាគីនោះ។

## ជំពូក ៦
## សហប្រតិបត្តិការឆ្លងដែន

### មាត្រា ១៩
### បទបញ្ញត្តិទូទៅ

យោងតាមកិច្ចព្រមព្រៀងទៅវិញទៅមកដោយស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រ ៤៨ មន្ត្រីនៃភាគីហត្ថលេខី អាចចូលរួមក្នុងសកម្មភាពណាមួយ ដូចមានចែងនៅក្នុងជំពូកនេះនៅក្នុងដែនដីនៃភាគីហត្ថលេខីផ្សេងទៀត និងអនុលោមតាមល័ក្ខខ័ណ្ឌបន្ថែមផ្សេងណាមួយ ដូចមានចែងដោយភាគីហត្ថលេខីនៃដែនដីដែលសកម្មភាពទាំងនោះកើតឡើង។ សកម្មភាពមួយចំនួន ត្រូវបញ្ឈប់ភ្លាមនៅពេលដែលភាគីហត្ថលេខីនៅក្នុងដែននោះចាប់ផ្តើមធ្វើសកម្មភាពតាមសំណើរ។

### មាត្រា ២០
### ការដេញតាមប្រកិត

១. មន្ត្រីនៃភាគីហត្ថលេខីមួយ ដែលកំពុងដេញតាមចាប់បុគ្គលម្នាក់នៅក្នុងដែនដីរបស់ភាគីមួយទៀត ដោយសង្កេតឃើញថាបុគ្គលនោះកំពុងប្រព្រឹត្តបទល្មើសគយដែលអាចបង្កើតជាបត្យាប័ន ឬធ្វើការចូលរួមក្នុងបទល្មើសនេះអាចបន្តដេញតាមនៅក្នុងដែនដីនៃភាគីហត្ថលេខីមួយផ្សេងតាមការស្នើសុំជាមុន ត្រូវគោរពតាមការអនុញ្ញាតនិងល័ក្ខខ័ណ្ឌទាំងឡាយដែលលើកឡើងដោយភាគីហត្ថលេខី។

២. ក្នុងករណីពិសេសនិងបន្ទាន់ ប្រសិនបើមិនអាចជំរាបជូនអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីផ្សេងមួយ មុនពេលចូលទៅដែនដីរបស់គេឬនៅពេលដែល

អាជ្ញាធរទាំងនោះមិនអាចចូលរួមក្នុងសកម្មភាពដេញតាមប្រកិតនេះ ការដេញតាមអាចបន្តដោយមិនចាំបាច់មានការអនុញ្ញាតិជាមុន ។

៣. ពេលមានការដេញតាមត្រូវបានបន្តដោយមិនមានការអនុញ្ញាតជាមុន ត្រូវជូនដំណឹងជាបន្ទាន់ ដល់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខី អំពីការដេញតាមត្រូវបានបន្តនៅក្នុងដែនដីរបស់គេការឆ្លងកាត់ព្រំដែន ហើយត្រូវដាក់សំណើរសុំការអនុញ្ញាតជាផ្លូវការជាបន្ទាន់ដោយបញ្ជាក់ ពីហេតុផលឱ្យបានច្បាស់លាស់នៃការឆ្លងព្រំដែនដោយមិនមានការអនុញ្ញាតជាមុន។

៤. តាមសំណើរនៃមន្ត្រីដែលធ្វើការដេញតាម អាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីដែលការដេញតាមកំពុងកើតឡើង ត្រូវសាកសួរបុគ្គលដែលកំពុងដេញតាមនោះ និងរកអត្តសញ្ញាណកម្មរបស់បុគ្គលនោះ ឬឃាត់ទុកបុគ្គលនោះ។

៥. នៅពេលដែលការដេញតាមលើផ្ទៃសមុទ្ទ ដែលបន្តដល់លំហសមុទ្ទ កិច្ចការនេះត្រូវអនុវត្តដោយអនុលោមតាមច្បាប់សមុទ្ទអន្តរជាតិ ដូចមានចែងនៅក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្ទ។

## មាត្រា ២១
## ការឃ្លាំមើលឆ្លងដែន

១. មន្ត្រីនៃភាគីហត្ថលេខីមួយ កំពុងបន្តឃ្លាំមើលនៅក្នុងដែនដីរបស់គេចំពោះបុគ្គលមួយដែលគេមានហេតុផល និងជឿជាក់ថាបុគ្គលនោះពាក់ព័ន្ធនឹងបទល្មើសគយ អាចបន្តឃ្លាំមើលនៅក្នុងដែនដីនៃភាគីហត្ថលេខីផ្សេងមួយទៀតបាន ដោយមានការស្នើសុំជាមុន ហើយត្រូវគោរពតាមការអនុញ្ញាត និងល័ក្ខខ័ណ្ឌទាំងឡាយដែលលើកឡើងដោយភាគីហត្ថលេខីទទួលសំណើនោះ។

២. ក្នុងករណីពិសេសនិងបន្ទាន់ ប្រសិនបើគ្មានការសុំអនុញ្ញាតជាមុនការឈ្លបមើលអនុលោមទៅតាមកថាខ័ណ្ឌទី ១ នៃមាត្រានេះ អាចត្រូវបានបន្តបានដោយត្រូវរាយការណ៍ជាបន្ទាន់ និងដាក់សំណើរសុំការអនុញ្ញាតជាផ្លូវការតាមលទ្ធភាពដែលអាចធ្វើទៅបានដោយបញ្ជាក់នូវមូលហេតុ អំពីការឆ្លងកាត់ព្រំដែនដោយ

គ្មានការអនុញ្ញាតជាមុនដល់អាជ្ញាធរមានសមត្ថកិច្ច នៃភាគីហត្ថលេខីដែលដែនដីរបស់ភាគីនេះត្រូវបានបន្តឃ្លាំមើល។

## មាត្រា ២២
## ប្តូរការស៊ើបអង្កេត

១. ភាគីហត្ថលេខីទទួលសំណើ អាចអនុញ្ញាតឱ្យបណ្តាមន្ត្រីនៃភាគីស្នើសុំធ្វើការស៊ើបអង្កេតនៅក្នុងដែនដីរបស់ខ្លួន ស្វែងរកការសម្គាល់នៃអត្តសញ្ញាណក្លែងក្លាយឬបញ្ជាក់ពីការពិតអំពីបទល្មើសគយ ដែលជាការលំបាកស្មុគស្មាញ។ មន្ត្រីទាំងឡាយនេះគឺត្រូវបានអនុញ្ញាតឱ្យប្រមូលព័ត៌មាន និងធ្វើការទំនាក់ទំនងជាមួយប្រធានបទនៃការស៊ើបអង្កេត ឬជាមួយបុគ្គលផ្សេងទៀត ដែលទាក់ទិនជាមួយពួកគេក្នុងកំឡុងពេលធ្វើការស៊ើបអង្កេតរបស់ពួកគេ។

២. ការស៊ើបអង្កេតបែបនោះត្រូវបានអនុវត្តដោយអនុលោមតាមច្បាប់ និងនីតិវិធីរបស់ភាគីហត្ថលេខីដែលជាដែនដីត្រូវដឹកនាំធ្វើការស៊ើបអង្កេត។

## មាត្រា ២៣
## ការត្រួតពិនិត្យរួមគ្នា និងក្រុមស៊ើបអង្កេត

១. ភាគីហត្ថលេខីទាំងឡាយ អាចបង្កើតឱ្យមានការត្រួតពិនិត្យរួមគ្នាឬជាក្រុមស៊ើបអង្កេតដើម្បីស្វែងរក និងបង្ការនូវប្រភេទពិសេសនៃបទល្មើសគយ ទាមទារឱ្យធ្វើសកម្មភាពដំណាលគ្នា និងសម្របសម្រួលគ្នា។

២. ក្រុមទាំងនេះ ត្រូវបានប្រតិបត្តិដោយអនុលោមតាមច្បាប់ និងនីតិវិធីរបស់ភាគីហត្ថលេខីដែលជាដែនដីត្រូវធ្វើសកម្មភាពស៊ើបអង្កេត។

## ជំពូក ៧
## ការប្រើប្រាស់ ការរក្សាការសម្ងាត់ ការការពារព័ត៌មាន

### មាត្រា ២៤
### ការប្រើប្រាស់ព័ត៌មាន

១. ដោយមិនប៉ះពាល់ដល់មាត្រា ៣៦ រាល់ព័ត៌មានដែលបានទំនាក់ទំនងក្រោមអនុសញ្ញានេះ ត្រូវប្រើប្រាស់សំរាប់តែរដ្ឋបាលគយតែប៉ុណ្ណោះ ដែលវាជាគោលបំណងតែមួយគត់សំរាប់ជំនួយផ្នែករដ្ឋបាល តាមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងអនុសញ្ញានេះ ។

២. ក្រៅពីកថាខ័ណ្ឌទី ១ នៃមាត្រានេះ តាមសំណើរ ភាគីហត្ថលេខីដែលជាអ្នកបានផ្តល់ព័ត៌មាន អាចអនុញ្ញាតឱ្យប្រើព័ត៌មានរបស់ខ្លួនសំរាប់គោលបំណងផ្សេង ឬបណ្តាអាជ្ញាធរផ្សេង យោងទៅតាមល័ក្ខខ័ណ្ឌដែលអាចបញ្ជាក់ច្បាស់លាស់។ ការប្រើប្រាស់បែបនេះ ត្រូវអនុលោមតាមបទបញ្ញត្តិច្បាប់និងរដ្ឋបាល នៃភាគីហត្ថលេខីដែលស្វែងរកការប្រើប្រាស់ព័ត៌មាន។ ការប្រើប្រាស់ព័ត៌មាន សំរាប់គោលបំណងផ្សេង រួមទាំងការប្រើប្រាស់នៅក្នុងការស៊ើបអង្កេតរឿងឧក្រិដ្ឋកម្ម បណ្តឹង សាធារណៈ និងរឿងក្តី ។

### មាត្រា ២៥
### ការសម្ងាត់ និងការការពារពត៌មាន

១. រាល់ព័ត៌មានដែលបានទំនាក់ទំនងក្រោមអនុសញ្ញានេះ ត្រូវបានចាត់ទុកថាជាការសម្ងាត់ ហើយយ៉ាងហោចណាស់ត្រូវមានការការពារ និងរក្សាការសម្ងាត់ដូចគ្នានូវប្រភេទព័ត៌មានដូចគ្នា គឺត្រូវស្របតាមបទបញ្ញត្តិច្បាប់ជាតិនិងរដ្ឋបាល នៃភាគីហត្ថលេខីដែលបានទទួលព័ត៌មាន។

២. យោងតាមកិច្ចព្រមព្រៀងទៅវិញទៅមកដោយស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ៤៨ ការផ្លាស់ប្តូរទិន្នន័យផ្ទាល់ខ្លួនរវាងភាគីហត្ថលេខីពីរឬច្រើនក្នុងអនុសញ្ញានេះ មិនអាចចាប់ផ្តើមបានទេ លុះត្រាភាគីហត្ថលេខីពាក់ព័ន្ធបានសម្រេចចិត្តថា

ទទួលទិន្នន័យទាំងនេះនៅក្នុងដែនដីនៃភាគីហត្ថលេខីដែលទទួលព័ត៌មានកំរិតនៃការការពារដែលឆ្លើយតបទៅនឹងការទាមទារនៃច្បាប់ជាតិ របស់ភាគីហត្ថលេខីដែលផ្តល់ព័ត៌មាន ។

៣. ក្នុងករណីខកខាននៃកិច្ចព្រមព្រៀងទៅវិញទៅមក ដោយយោងតាមកថាខ័ណ្ឌទី ២ នៃមាត្រានេះ ភាគីហត្ថលេខីផ្តល់ព័ត៌មាន អាចផ្តល់ទិន្នន័យផ្ទាល់ខ្លួនបាន លុះត្រាតែទិន្នន័យផ្ទាល់ខ្លួនត្រូវបាន ការពារនៅក្នុងដែនដីនៃភាគីហត្ថលេខីដែលទទួលព័ត៌មាន ដោយអនុលោមតាមបទបញ្ញត្តិនៃអនុសញ្ញានេះ។

៤. ក្នុងពេលចុះហត្ថលេខា សច្ចានុមតិឬការចូលជាសមាជិកដល់អនុសញ្ញានេះ ភាគីហត្ថលេខី ត្រូវជំរាបជូនអគ្គលេខាធិការជាលាយលក្ខណ៍អក្សរនៃបទបញ្ញត្តិច្បាប់និងរដ្ឋបាលរបស់ខ្លួនពាក់ព័ន្ធនឹងព័ត៌មានសម្ងាត់ និងការការពារទិន្នន័យផ្ទាល់ខ្លួន។ ក្នុងពេលចុះហត្ថលេខា សច្ចានុមតិឬការចូលជាសមាជិក ភាគីហត្ថលេខីទាំងអស់ ត្រូវប្រកាសជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការពីការប្តេជ្ញារបស់ខ្លួន យ៉ាងហោចណាស់ការគោរពបទបញ្ញត្តិរក្សាព័ត៌មានសម្ងាត់ និងការការពារទិន្នន័យផ្ទាល់ខ្លួននៃអនុសញ្ញានេះ។

## មាត្រា ២៦
## ការការពារទិន្នន័យផ្ទាល់ខ្លួន

១. ទិន្នន័យផ្ទាល់ខ្លួន អាចត្រូវបានផ្តល់អោយទៅរដ្ឋបាលគយតែមួយប៉ុណ្ណោះ។ ការផ្តល់ទិន្នន័យ ផ្ទាល់ខ្លួននេះទៅអោយអាជ្ញាធរផ្សេងទៀត អាចអនុញ្ញាតឱ្យបានប្រសិនបើមានការយល់ព្រម ជាមុនពីរដ្ឋបាលគយដែលផ្គត់ផ្គង់ទិន្នន័យពាក់ព័ន្ធនេះ។

២. តាមការស្នើសុំ រដ្ឋបាលគយដែលទទួលទិន្នន័យផ្ទាល់ខ្លួននេះ ត្រូវជូនព័ត៌មានទៅឱ្យរដ្ឋបាលគយដែលផ្គត់ផ្គង់ព័ត៌មាន អំពីការប្រើប្រាស់ព័ត៌មានទាំងនេះព្រមទាំងលទ្ធផលដែលសំរេចបាន។

៣. ទិន្នន័យផ្ទាល់ខ្លួនដែលបានផ្តល់អោយស្ថិតក្រោមអនុសញ្ញានេះ ត្រូវតែរក្សាទុកសំរាប់រយៈពេលចាំបាច់មួយ ដើម្បីសំរេចបានតាមគោលបំណងនៃការផ្តល់ឱ្យ។

៤. រដ្ឋបាលគយដែលផ្គត់ផ្គង់ទិន្នន័យផ្ទាល់ខ្លួននេះ តាមលទ្ធភាពដែលអាចធ្វើទៅបាន ត្រូវធានាថាទិន្នន័យនេះត្រូវបានប្រមូលដោយត្រឹមត្រូវស្របតាមច្បាប់ ហើយថាទិន្នន័យនោះត្រឹមត្រូវនិងទាន់សម័យ ព្រមទាំងមិនលើសពីគោលបំណងនៃផ្គត់ផ្គង់អោយឡើយ។

៥. ប្រសិនបើទិន្នន័យផ្ទាល់ខ្លួនដែលបានផ្តល់អោយ ត្រូវបានគេរកឃើញថាមិនត្រឹមត្រូវឬត្រូវបានគេដោះដូរនោះបញ្ហានេះត្រូវតែជូនដំណឹងវិញជាបន្ទាន់។ រដ្ឋបាលគយដែលទទួលទិន្នន័យនេះ ត្រូវតែធ្វើការកែប្រែឬលុបទិន្នន័យនោះចោល។

៦. រដ្ឋបាលគយ ត្រូវតែកត់ត្រាទុកពីការផ្តល់អោយឬការទទួលទិន្នន័យផ្ទាល់ខ្លួនដែលត្រូវបានដោះដូរក្នុងអនុសញ្ញានេះ ។

៧. រដ្ឋបាលគយ ត្រូវតែចាត់វិធានការសុវត្ថិភាពចាំបាច់នានា សំរាប់ការពារទិន្នន័យផ្ទាល់ខ្លួនដែល ត្រូវបានដោះដូរក្នុងអនុសញ្ញានេះពីការចូលប្រើទិន្នន័យដោយគ្មានការអនុញ្ញាត ការកែប្រែ ឬការផ្សព្វផ្សាយ។

៨. ភាគីហត្ថលេខីត្រូវទទួលខុសត្រូវដោយយោងតាមបញ្ញត្តិច្បាប់និងរដ្ឋបាល ចំពោះការខូចខាតដែលបង្កឡើងចំពោះបុគ្គលណា ម្នាក់តាមរយៈការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនដែលផ្លាស់ប្តូរនៅក្នុងអនុសញ្ញានេះ។ វាជាបញ្ហាផងដែរ នៅពេលដែលការខូចខាតបណ្តាលមកពីភាគីហត្ថលេខីផ្តល់ទិន្នន័យមិនត្រឹមត្រូវ ឬផ្ទុយនឹងអនុសញ្ញានេះ ។

៩. ប្រសិនបើភាគីហត្ថលេខីបានរកឃើញថា ត្រូវទទួលខុសត្រូវចំពោះការខូចខាតស្របតាមកថាខ័ណ្ឌទី ៨ នៃមាត្រានេះ មិនមែនជាភាគីហត្ថលេខីដែលផ្តល់ទិន្នន័យផ្ទាល់ខ្លួននោះទេ នោះភាគីហត្ថលេខីពាក់ព័ន្ធ ត្រូវតែយល់ព្រមតាមល័ក្ខខ័ណ្ឌដែលបានចែងដោយសងដល់ភាគីហត្ថលេខី ដែលត្រូវទទួលខុសត្រូវនោះនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវចូទាត់ជាសំណង។

## ជំពូក ៨
## មជ្ឈការនៃព័ត៌មាន
### មាត្រា ២៧
### គោលបំណងនៃមជ្ឈការ

១. យោងតាមមាត្រាទី ២៨, ២៩ និង ៣០ ព័ត៌មាន ត្រូវរក្សាទុកក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មាន ស្វ័យប្រវត្តិកម្មដែលជាកន្លែងធានាសុវត្ថិភាពមួយក្នុងគោលបំណងនៃការគ្រប់គ្រងហានិភ័យ ដើម្បីធានាដល់ការអនុវត្តច្បាប់គយយ៉ាងត្រឹមត្រូវសំរាប់ការទប់ស្កាត់ ស៊ើបអង្កេត និងបង្ក្រាប បទល្មើសគយ ព្រមទាំងធានាដល់សន្តិសុខខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិ។

៤. ទិន្នន័យផ្ទាល់ខ្លួនត្រូវរក្សាទុកផងដែរ ក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មដែលជាកន្លែងមានសុវត្ថិភាពមួយ ក្នុងគោលបំណងនៃការផ្តល់ពត៌មាន អំពីបុគ្គលដែលបានប្រព្រឹត្ត ឬមានការសង្ស័យថានឹងនឹងប្រព្រឹត្តបទល្មើសគយ។

### មាត្រា ២៨
### ព័ត៌មានមិនផ្ទាល់ខ្លួន

១. គោលបំណងនៃមាត្រា ២៧ និង ៣១ និង ប្រសិនបើច្បាប់ជាតិអនុញ្ញាតរដ្ឋបាលគយ ត្រូវតែទាក់ទងនឹងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម អំពីព័ត៌មានមិនមែនមានលក្ខណៈជាបុគ្គល ឬផ្ទាល់ខ្លួន ដូចខាងក្រោម :

i. ព័ត៌មានដែលយោងដល់រឿងហេតុ ប្រសិនបើសមស្រប
ii. មុខទំនិញ
iii. បរិមាណ និងឯកតារង្វាស់
iv. មធ្យោបាយដឹកជញ្ជូន
v. មធ្យោបាយលាក់/បិទបាំង
vi. ការចង្អុលថាតើទំនិញត្រូវបានគេរកឃើញនៅពេលនាំចូល/នាំចេញ ឆ្លងកាត់ឬក្នុងប្រទេស
vii. គំរាយផ្លូវ

viii. មធ្យោបាយបិទបាំង

២. គណៈកម្មាធិការរដ្ឋបាល ត្រូវមានសិទ្ធិអំណាចដើម្បីកែប្រែបញ្ជីក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ។

## មាត្រា ២៩..

## ព័ត៌មានអំពីរូបវ័ន្តបុគ្គលនិងនីតិបុគ្គល

១. គោលបំណងនៃមាត្រា ២៧ និង ៣១ និង ប្រសិនបើច្បាប់ជាតិអនុញ្ញាត្ត រដ្ឋបាលគយ ត្រូវទាក់ទងនឹងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម អំពីព័ត៌មានដូចខាងក្រោម :

**ក. អំពីរូបវ័ន្តបុគ្គលៈ**

i. នាមត្រកូលនិងនាមខ្លួន និងឈ្មោះហៅក្រៅ ឈ្មោះពីមុន ប្រសិនបើមាន

ii. ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត

iii. សញ្ជាតិ

iv. ប្រភេទ និងលេខប័ណ្ណសំគាល់ខ្លួន

v. ភេទ

vi. ប្រទេសនិវេសនដ្ឋាន

vii. ប្រភេទនៃបទល្មើស

viii. មុខរបរ

ix. លក្ខណៈពិសេសឬភិនភាគផ្សេងៗ

x. ប្រវត្តិពីមុន និងព័ត៌មានអំពីការសង្ស័យ

xi. លេខសំគាល់មធ្យោបាយដឹកជញ្ជូន

xii. ការចង្អុលបង្ហាញអំពីកំរិតគ្រោះថ្នាក់ដែលបុគ្គលនោះអាចបង្កឡើង

xiii. មូលហេតុច្បាស់លាស់នៃការបញ្ចូលទិន្នន័យ

xiv. អង្គការឧក្រិដ្ឋកម្មដែលបំរើ

xv. អង្គការ សមាគមនីពាកព័ន្ធផ្សេងទៀត

**ខ. អំពីនីតិបុគ្គលៈ**

i. នាម និង ពាណិជ្ជនាម
ii. ប្រទេសចុះបញ្ជី
iii. លេខចុះបញ្ជី
iv. កាលបរិច្ឆេទចុះបញ្ជី
v. ការិយាល័យចុះបញ្ជី
vi. អាសយដ្ឋានធ្វើពាណិជ្ជកម្ម
vii. ទំរង់នៃអាជីវកម្ម
viii. ទំរង់នៃបទល្មើស
ix. ប្រវត្តិពីមុន ឬព័ត៌មាន ស្តីពី នីតិបុគ្គលដែលជាប់សង្ស័យ
x. មូលហេតុជាក់លាក់ សំរាប់ការបញ្ចូលទិន្នន័យ
xi. ឈ្មោះមន្ត្រីជាន់ខ្ពស់ ឬបុគ្គលិក និងប្រសិនបើត្រឹមត្រូវ ព័ត៌មានបញ្ជាក់ណាមួយដូចមានចែងនៅក្នុងកថាខ័ណ្ឌ (ក)i ដល់ xi។

២. គណៈកម្មការរដ្ឋបាល ត្រូវមានសិទ្ធិអំណាចធ្វើការកែប្រែបញ្ជីនៅក្នុងកថាខ័ណ ទី ១(ក) និង (ខ) នៃមាត្រានេះ។

### មាត្រា ៣០
### ព័ត៌មានផ្សេងៗ

រដ្ឋបាលគយ អាចធ្វើទំនាក់ទំនងទៅមជ្ឈមណ្ឌលប្រពន្ធ័ព័ត៌មានស្វ័យប្រវត្តិកម្ម ប្រសិនបើមានការអនុញ្ញាតពីច្បាប់ជាតិរបស់ខ្លួន ព័ត៌មានណាមួយផ្សេងទៀតដែលអាចពាក់ព័ន្ធសំរាប់ការអនុវត្តច្បាប់ គយឱ្យបានត្រឹមត្រូវ សំរាប់ការទប់ស្កាត់ ការស៊ើបអង្កេត និងការប្រយុទ្ធប្រឆាំងបទល្មើសគយ និងសំរាប់ធានាសន្តិសុខនៃខ្សែចង្វាក់ផ្គត់ផ្គង់ពាណិជ្ជកម្មអន្តរជាតិនេះ។

### មាត្រា ៣១
### មជ្ឈមណ្ឌលប្រពន្ធ័ព័ត៌មានស្វ័យប្រវត្តិកម្ម

១. យោងទៅតាមមាត្រា ២៨, ២៩ និង ៣០ ព័ត៌មាន ត្រូវរក្សាទុកក្នុងមជ្ឈមណ្ឌលប្រពន្ធ័ព័ត៌មាន ស្វ័យប្រវត្តិកម្មដែលជាកន្លែងមានសុវត្ថិភាពសំរាប់គោល

ដៅរបស់គេយ។ ប្រពន្ធ័នេះ ត្រូវធ្វើការចាត់ចែងពីទីស្នាក់ការកណ្តាលរបស់ក្រុមប្រឹក្សានិងអាចទទួលយកបាន យោងតាមច្បាប់ដែលបានចែងនៅក្នុងមាត្រា៣៨។

២. ការទាក់ទងព័ត៌មានដោយភាគីហត្ថលេខីមួយទៅកាន់មជ្ឈមណ្ឌលប្រពន្ធ័ព័ត៌មានស្វ័យប្រវត្តិកម្ម ត្រូវស្ថិតក្រោមបទបញ្ញត្តិច្បាប់និងរដ្ឋបាលរបស់ភាគីហត្ថលេខីលុះត្រាតែអនុសញ្ញានេះ មានបទបញ្ញត្តិដ៏ទៃបន្ថែម។

៣. ភាគីកិច្ចហត្ថលេខីនីមួយៗ ត្រូវចាត់តាំងអាជ្ញាធរមានសមត្ថកិច្ចមួយនៅក្នុងរដ្ឋបាលរបស់ខ្លួន ដើម្បីទទួលខុសត្រូវនៅចំពោះមុខថ្នាក់ជាតិសំរាប់ប្រតិបត្តិការត្រឹមត្រូវនៃមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម និងសំរាប់វិធានការចំបាច់ដើម្បីធានាឱ្យមានការប្រព្រឹត្តស្របច្បាប់ យោងតាមបទបញ្ញត្តិក្នុងជំពូក VIII និងX ។

៤. អគ្គលេខាធិការ ត្រូវចាត់តាំងមន្ត្រីក្រុមប្រឹក្សាដើម្បីទទួលខុសត្រូវនៅក្រុមប្រឹក្សាសំរាប់ប្រតិបត្តិការត្រឹមត្រូវ និង ការថែទាំនៃមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម និង សំរាប់វិធានការជាចាំបាច់ដើម្បីធានាមានការប្រព្រឹត្តស្របតាមបញ្ញត្តិនៃជំពូកទី VIII និង X ។

៥. ភាគីជាប់កិច្ចហត្ថលេខីនីមួយៗ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ អំពីអាជ្ញាធរមានសមត្ថកិច្ច ដែលខ្លួនបានចាត់តាំងស្របតាមកថាខ័ណ្ឌទី ៣ នៃមាត្រានេះ ដែលជាអ្នកផ្តល់ព័ត៌មាននេះដល់ភាគីហត្ថលេខីផ្សេងទៀត ស្របតាមព័ត៌មានដែលមានទាក់ទងនឹងមន្ត្រីក្រុមប្រឹក្សា ដែលបានចាត់តាំង ស្របតាមកថាខ័ណ្ឌទី ៤ នៃមាត្រានេះ។ ព័ត៌មាននេះ យោងតាមកថាខ័ណ្ឌនេះ ត្រូវរួមបញ្ចូលទាំងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ប៉ុន្តែមិនស្ថិតនៅក្រោមបញ្ញត្តិនៃជំពូក VII ទេ។

## មាត្រា ៣២
## ការគ្រប់គ្រងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម

១. ត្រូវបង្កើតក្រុមមួយឡើងដើម្បីគ្រប់គ្រងមជ្ឈមណ្ឌលប្រពន្ធ័ព័ត៌មានស្វ័យប្រវត្តិកម្ម ដោយយោងទៅលើកិច្ចការបច្ចេកទេសប្រតិបត្តិការនិងនីតិវិធី។ ក្រុមនេះ ត្រូវ

មានតំណាងមកពីរដ្ឋបាលគយនៃភាគីហត្ថលេខី និងមន្ត្រីក្រុមប្រឹក្សា។ សមាសភាពក្រុមដឹកនាំគ្រប់គ្រង ត្រូវសំរេចដោយគណៈកម្មាធិការរដ្ឋបាល។

២. ក្រុមគ្រប់គ្រង ត្រូវបង្កើតនីតិវិធីសំរាប់កិច្ចការបច្ចេកទេសនិងប្រតិបត្តិការ រួមទាំងនីតិវិធីដែលទាក់ទងនឹង :

(ក). ការទំនាក់ទំនងព័ត៌មាន ដោយស្របតាមមាត្រា ២៨, ២៩ និង ៣០។

(ខ). ការចូលប្រើប្រាស់ព័ត៌មានក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម និងព័ត៌មានដែលមាននៅក្នុងប្រព័ន្ធនោះ យោងតាមមាត្រាទី ៣៨ និង

(គ). ការប្រែព័ត៌មាន យោងតាមបទបញ្ញត្តិនៃមាត្រា ៣៩ និង ៤០ ។

៣. ដោយមានការយល់ព្រមពីគណៈកម្មាធិការរដ្ឋបាលនៃនីតិវិធីស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រានេះ ក្រុមគ្រប់គ្រងត្រូវធានាដល់ការអនុវត្តរបស់ពួកគេ។

៤. ក្រុមគ្រប់គ្រង ត្រូវរាយការណ៍យ៉ាងហោចណាស់ ១ ឆ្នាំម្តង ទៅគណៈកម្មាធិការរដ្ឋបាល ស្តីពី ការគ្រប់គ្រងនៃមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មស្របតាមកថាខ័ណ្ឌទី ១, ២ និងទី៣ នៃមាត្រានេះ ដោយផ្តល់ជាអនុសាសន៍នៅពេលណាដែលចាំបាច់។

## ជំពូក ៩

## សន្តិសុខនៃមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម

### មាត្រា ៣៣

### ការទទួលខុសត្រូវលើវិធានការសន្តិសុខ

១. ភាគីហត្ថលេខីនិងអគ្គលេខាធិការ ត្រូវតែទទួលខុសត្រូវក្នុងការអនុវត្តវិធានការចាំបាច់នានាសំរាប់សន្តិសុខនៃមជ្ឈមណ្ឌលប្រព័ន្ធព័តមានស្វ័យប្រវត្តិកម្ម។ គោលបំណងនៃវិធានការទាំងនេះ ត្រូវបានដាក់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះ:

(ក). ការបង្ការមិនអោយអ្នកគ្មានសិទ្ធិចូលប្រើប្រាស់ឧបករណ៍សំរាប់ដំណើរការប្រព័ន្ធព័ត៌មាន ។

(ខ). ការបង្ការ មិនអោយអ្នកគ្មានសិទ្ធិចូលក្នុងប្រព័ន្ធ។

(គ). ការបង្ការ មិនអោយអ្នកគ្មានសិទ្ធចូលអាន ថតចំលង កែប្រែឬលុប ទិន្នន័យផ្សេងៗក្នុងប្រព័ន្ធឡើយ។

(ឃ). ស្របតាមកថាខ័ណ្ឌទី ១ នៃមាត្រា ៣៨ ត្រូវធានាថាវាមានលទ្ធភាព អាចពិនិត្យមើលនិងអាចឱ្យអាជ្ញាធរមានសមត្ថកិច្ចដែលបានចាត់តាំង និង មន្ត្រីក្រុមប្រឹក្សាមានសិទ្ធចូល ប្រើប្រាស់មជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យ ប្រវត្តិកម្ម និងយោងតាមកថាខ័ណ្ឌទី ២ នៃមាត្រា៣៨ មន្ត្រីដែលមាន ការចាត់តាំងនិងមន្ត្រីក្រុមប្រឹក្សាមានសិទ្ធិអាចចូលប្រើ ប្រាស់ព័ត៌មាននៅ ក្នុងប្រព័ន្ធនោះបាន។

(ង). ការធានាថាវាមានលទ្ធភាពដើម្បីត្រួតពិនិត្យមើល និងបើកមើលព័ត៌មាន នៅក្នុងប្រព័ន្ធបាននៅពេលព័ត៌មានបានដាក់ចូលក្នុងប្រព័ន្ធរួចរាល់ហើយ ដោយនរណាម្នាក់និងត្រួតពិនិត្យមើលលើសំណួរ។

(ច). ការបង្ការដល់អ្នកគ្មានសិទ្ធិអាន ថតចំលង កែប្រែ លុបចោលព័ត៌មាន ក្នុងកំឡុងពេលកំពុងធ្វើការទាក់ទងនឹងទិន្នន័យ និងពេលកពុងបញ្ជូន ព័ត៌មានទិន្នន័យនានា។

២. អ្នកតំណាងឯករាជ្យ ឬអ្នកតំណាងដែលបានចាត់តាំង ស្របតាមកថាខ័ណ្ឌទី ១(ច) នៃមាត្រា ៤៥ ត្រូវធ្វើការផ្ទៀងផ្ទាត់ចំពោះការចូលប្រើប្រាស់ និងសាក សួរអំពីទិន្នន័យផ្ទាល់ខ្លួន ដោយធានាថាការចូលប្រើប្រាស់ និងសាកសួរទាំងនេះ បានទទួលការអនុញ្ញាត និងមានសិទ្ធិប្រើ ប្រាស់។ ការកត់ត្រានៃការផ្ទៀងផ្ទាត់ ត្រូវរក្សាក្នុងប្រព័ន្ធសំរាប់ធ្វើរបាយការណ៍ជូនគណៈកម្មាធិការរដ្ឋបាល និងលុប ចោលបានបន្ទាប់ពីរយៈពេល ១២ខែ ក្រោយមក។

## មាត្រា ៣៤

## អនុវត្តន៍វិធានការសន្តិសុខ

១. ភាគីហត្ថលេខី ត្រូវចាត់តាំងអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងរដ្ឋបាលគយកំរិត ជាតិដើម្បីចាត់វិធានការសន្តិសុខស្របតាមកថាខ័ណ្ឌទី(១) នៃមាត្រា ៣៣។

២. អគ្គលេខាធិការ ត្រូវចាត់តាំងមន្ត្រីក្រុមប្រឹក្សាក្នុងកិរិតក្រុមប្រឹក្សា ដើម្បីចាត់វិធានការសន្តិសុខ ស្របតាមកថាខ័ណ្ឌទី (១) នៃមាត្រា ៣៣។

៣. ភាគីហត្ថលេខីនីមួយៗត្រូវជូនដំណឹងទៅអគ្គលិខាធិការនូវអាជ្ញាធរមានសមត្ថកិច្ច ដែលបានចាត់តាំងស្របទៅតាមកថាខ័ណ្ឌទី (១) នៃមាត្រានេះ ហើយត្រូវជូននូវព័ត៌មាននេះទៅភាគីហត្ថលេខីផងទៀត ជាមួយនឹងព័ត៌មានការចាត់តាំងមន្ត្រីរបស់ក្រុមប្រឹក្សា ស្របតាមកថាខ័ណ្ឌទី (១) នៃមាត្រនេះ។ ព័ត៌មានទាំងឡាយក្នុងកថាខ័ណ្ឌនេះ ត្រូវបានបញ្ចូលក្នុងមជ្ឈមណ្ឌលប្រព័ន្ធព៌តមានស្វ័យប្រវត្តិកម្ម ប៉ុន្តែមិនដូចគ្នានឹងបទបញ្ញត្តិជំពូក ៧ ឡើយ ។

## ជំពូក ១០

## ការការពារព័ត៌មានក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម

### មាត្រា ៣៥

### ការបញ្ចូលពត៌មាន

ការបញ្ចូលព័ត៌មានទៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធស្វ័យព័ត៌មានប្រវត្តិកម្មត្រូវគ្រប់គ្រងដោយបទបញ្ញត្តិច្បាប់និងរដ្ឋបាល នៃភាគីហត្ថលេខីដែលបានផ្តល់ លើកលែងតែមានចែងយ៉ាងតឹងរឹងបន្ថែមក្នុងអនុសញ្ញានេះ។

### មាត្រា ៣៦

### ការប្រើប្រាស់ពត៌មាន

១. ការប្រើប្រាស់ព័ត៌មានដែលទទួលបានពីមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ត្រូវគ្រប់គ្រងដោយបទបញ្ញត្តិច្បាប់ និងរដ្ឋបាលរបស់ភាគីហត្ថលេខី សំរាប់ការប្រើប្រាស់ព័ត៌មានទាំងនេះ លើកលែងតែមានចែងក្នុងបទបញ្ញត្តិយ៉ាងតឹងរឹងក្នុងអនុសញ្ញានេះ។

២. ភាគីហត្ថលេខី អាចប្រើប្រាស់ព័ត៌មានដែលទទួលបានពីមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ដើម្បីយកប្រើតាមគោលបំណងនានារបស់ខ្លួន ដូចបាន

ចែងក្នុងមាត្រា ២៧។ ទោះជាយ៉ាងនេះក៏ដោយ តាមសំណើ ភាគីហត្ថលេខី ដែលផ្តល់ព័ត៌មានអាចមានសិទ្ធិប្រើប្រាស់វាសំរាប់គោលបំណងផ្សេងទៀតដោយ យោងតាមលក្ខខណ្ឌនានាអាចបញ្ជាក់។ ការប្រើប្រាស់ផ្សេងៗ ទៀតត្រូវស្រប តាមបទបញ្ញត្តិច្បាប់និងរដ្ឋបាល នៃភាគីហត្ថលេខីដែលស្នើសុំប្រើប្រាស់ព័ត៌មាន ទាំងនេះ។ ការប្រើប្រាស់ព័ត៌មានសំរាប់គោលបំណងផ្សេងទៀត រួមទាំងការ ប្រើប្រាស់សំរាប់ស៊ើបអង្កេតបទឧក្រិដ្ឋកម្ម បណ្តឹងសាធារណៈ ឬរឿងក្តី ផ្សេងៗ។

៣. ក្រោមការទទួលខុសត្រូវរបស់អគ្គលេខាធិការ មន្ត្រីក្រុមប្រឹក្សា អាចប្រើប្រាស ព័ត៌មានដែលទទួលបានពីមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ដោយគ្រាន់ តែយកមកអនុវត្តតាមកាតព្វកិច្ច ដូចមានចែងនៅក្នុងអនុសញ្ញានេះ តែប៉ុណ្ណោះ ដោយយោងតាមលក្ខខណ្ឌរបស់គណៈ កម្មាធិការរដ្ឋបាលអាចត្រូវដាក់អោយ អនុវត្ត។

៤. ទិន្នន័យផ្ទាល់ខ្លួន អាចត្រូវបានយកមកប្រើប្រាស់បានប្រសិនបើទទួលបានពីមជ្ឈ មណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មដោយស្របជាមួយកថាខណ្ឌទី ៧ នៃ មាត្រា ៣៨ ។

## មាត្រា ៣៧
## ការរក្សាទុកទិន្នន័យផ្ទាល់ខ្លួន

១. ទិន្នន័យផ្ទាល់ខ្លួនបានដាក់បញ្ចូលក្នុងមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្ម ត្រូវរក្សាទុក សំរាប់តែពេលវេលាចាំបាច់ដើម្បីសំរេចបំណងដែលវាផ្តល់អោយ តែប៉ុណ្ណោះ។ ភាគីហត្ថលេខី ត្រូវបញ្ជាក់ពីរយៈពេលដែលរក្សាទុកក្នុងប្រព័ន្ធនូវ ទិន្នន័យផ្ទាល់ខ្លួនបានផ្តល់អោយនេះ។

២. ការផ្តល់អោយរបស់ភាគីហត្ថលេខីអាចពន្យាររយៈពេលរក្សាទុក ដោយយោងក្នុង កថាខណ្ឌទី ១ នៃមាត្រានេះ ប្រសិនបើការរក្សាទុកនូវទិន្នន័យផ្ទាល់ខ្លួនវា ចាំបាច់សំរាប់គោលបំណងនានាដែល ប្រព័ន្ធនោះបានផ្តល់អោយ។ ប្រសិនបើ គ្មានការពន្យាររយៈពេល ទិន្នន័យត្រូវលុបចោលពីមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មាន

ស្វ័យប្រវត្តិកម្មនៅតំណាក់កាលដំបូងដែលភាគីហត្ថលេខីបានផ្តល់ នូវទិន្នន័យផ្ទាល់ខ្លួន។

៣. អគ្គលេខាធិការ ត្រូវជូនដំណឹងទៅភាគីហត្ថលេខីពេលលុបទិន្នន័យផ្ទាល់ខ្លួនយោងតាមកថាខណ្ឌទី ២ នៃមាត្រានេះ ដោយធ្វើការជូនដំណឹងមុនមួយខែ។

៤. អ្នកតំណាងឯករាជ្យ ឬអ្នកតំណាងដែលបានតែងតាំងរួចក្នុងកថាខណ្ឌ ១(ច)នៃមាត្រា ៩៥ និងធ្វើការផ្ទៀងផ្ទាត់ ដើម្បីធានាថារយៈពេលរក្សាទុកនូវទិន្នន័យផ្ទាល់ខ្លួននៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មបានអនុវត្តត្រឹមត្រូវ។ ការកត់ត្រានៃការផ្ទៀងផ្ទាត់ទាំងអស់ ត្រូវរក្សាទុកនៅក្នុងប្រពន្ធ័នេះសំរាប់ធ្វើរបាយការណ៍ជូនគណៈកម្មាធិការរដ្ឋបាលឬលុបចោលក្នុងរយៈពេល ១២ ខែក្រោយ។

## មាត្រា ៣៨
## ការចូលប្រើប្រាស់

១. អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីក្រុមប្រឹក្សា ដែលបានតែងតាំងស្របជាមួយនឹងកថាខណ្ឌទី ៣ និងទី ៤ នៃមាត្រា ៣១ ត្រូវមានសិទ្ធិអាចចូលប្រើប្រាស់ព័ត៌មាននៅមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្ម។

២. គោលបំណងនៃមាត្រា ២៧ និងមិនធ្វើប៉ះពាល់ដល់កថាខណ្ឌទី៧ នៃមាត្រានេះ ភាគីហត្ថលេខី ត្រូវតែងតាំងមន្ត្រីក្នុងរដ្ឋបាលគយរបស់ខ្លួន និងអគ្គលេខាធិការ ត្រូវតែងតាំងមន្ត្រីក្រុមប្រឹក្សាដែលអាចចូលប្រើប្រាស់ប្រពន្ធ័ពត៌មានក្នុងមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្ម។

៣. ការចូលទៅប្រើប្រាស់ប្រពន្ធ័ ត្រូវស្របជាមួយនឹងនីតិវិធីនានាដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា៣២។ សំរាប់គោលបំណងក្នុងមាត្រា ៣២ ក្រុមអ្នកគ្រប់គ្រង អាចចូលទៅប្រើប្រាស់ព័ត៌មានក្នុងមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្មបាន។

៤. គណៈកម្មាធិការរដ្ឋបាល អាចអនុញ្ញាត្តិអោយអង្គការអន្តរជាតិ និងរដ្ឋាភិបាលតាមតំបន់ចូលទៅប្រើព័ត៌មានដែលមិនមែនជាព័ត៌មានផ្ទាល់ខ្លួនក្នុងមជ្ឈមណ្ឌល

ប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មបានដោយឈរលើគោលការណ៍ស្មើបតិការនិងត្រូវតាមលក្ខខ័ណ្ឌនានាដែលគណៈកម្មាធិការ រដ្ឋបាលអាចបញ្ជាក់ច្បាស់លាស់។

៥. អ្នកតំណាង ឬអ្នកតំណាងដែលបានតែងតាំងដោយគណៈកម្មាធិការរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌទី១(ច)នៃមាត្រា៤៥ ត្រូវអាចចូលទៅប្រើប្រាស់ព័ត៌មានមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្មបាន ។

៦. ភាគីហត្ថលេខីនីមួយៗ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការស្តីពី ការតែងតាំងមន្ត្រីរបស់ខ្លួនក្រោមកថាខ័ណ្ឌទី២ នៃមាត្រានេះ។ អគ្គលេខាធិការ ត្រូវផ្តល់ព័ត៌មានទៅដល់គ្រប់ភាគីហត្ថលេខីទាំងអស់ជាមួយនឹងព័ត៌មាននានាពាក់ពន្ធ័នឹងមន្ត្រីក្រុមប្រឹក្សា ដែលបានតែងតាំងក្នុងកថាខណ្ឌដូចគ្នានេះ។ ព័ត៌មានដូចមាននៅក្នុងកថាខណ្ឌនេះ ត្រូវបញ្ចូលទៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម។ ប៉ុន្តែ វាពុំមែនអាស្រ័យលើបទបញ្ញត្តិនៃជំពូកទី ៧ នោះទេ។

៧. ភាគីហត្ថលេខីទាំងអស់ ត្រូវកំណត់ឱ្យច្បាស់ថាតើនរណាខ្លះដែលអាចចូលប្រើព័ត៌មានបាន និងនរណាខ្លះដែលមិនអាចចូលទៅប្រើព័ត៌មានក្នុងប្រព័ន្ធទិន្នន័យផ្ទាល់ខ្លួនដែលគេផ្តល់អោយ។

៨. សិទ្ធិរបស់រូបវន្តបុគ្គល ដែលពាក់ព័ន្ធនឹងទិន្នន័យផ្ទាល់ខ្លួននៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្ម ជាពិសេសសិទ្ធិចូលទៅប្រើប្រាស់របស់គេត្រូវចូលជាធរមានដោយអនុលោមទៅតាមបទបញ្ញត្តិច្បាប់និងរដ្ឋបាល នៃភាគីហត្ថលេខីដែលត្រូវប្រើនូវសិទ្ធិទាំងនេះនៅក្នុងដែនដីរបស់គេ។

## មាត្រា ៣៩
## ការកែសំរួលព័ត៌មានមិនផ្ទាល់ខ្លួននៅក្នុងមជ្ឈមណ្ឌល ប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម

១. ព័ត៌មានមិនផ្ទាល់ខ្លួននៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ត្រូវកែសំរួលបញ្ចូលបន្ថែមកែសំរួលឬលុបចោលនៅពេលភាគីហត្ថលេខីផ្តល់ឱ្យដំបូង។

២. ព័ត៌មានមិនផ្ទាល់ខ្លួន ត្រូវកែសម្រួល បញ្ចូលបន្ថែម កែតម្រូវ ឬលុបចោលដោយយោងទៅតាមនីតិវិធី និងអនុវត្តដោយក្រុមគ្រប់គ្រង យោងតាមកថាខ័ណ្ឌទី ២ និងទី ៣ នៃមាត្រា ៣២។

## មាត្រា ៤០

## ការកែសម្រួលព័ត៌មានផ្ទាល់ខ្លួននៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម

១. ព័ត៌មានផ្ទាល់នៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្ម ត្រូវកែសម្រួល បញ្ចូលបន្ថែម កែតម្រូវ ឬលុបចោលនៅពេលភាគីហត្ថលេខីផ្តល់ឱ្យដំបូង។

២. ប្រសិនបើភាគីហត្ថលេខីកត់សំគាល់ឃើញថា ទិន្នន័យផ្ទាល់ខ្លួនដែលខ្លួនបានផ្តល់ឱ្យគឺមិនត្រឹមត្រូវ ឬត្រូវបានបញ្ចូលឬត្រូវបានផ្ទុកនៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មផ្ទុយនឹងអនុសញ្ញានេះ ទិន្នន័យទាំងនេះ ត្រូវរៀបចំការកែសម្រួលការបញ្ចូលបន្ថែម ការកែតម្រូវឬការលុបចេញនូវទិន្នន័យផ្ទាល់ខ្លួន ដោយគ្មានការយឺតយ៉ាវ។ ភាគីហត្ថលេខីពាក់ព័ន្ធ ត្រូវរៀបចំជាមួយអគ្គលេខាធិការធ្វើការជូនដំណឹងដល់ភាគីដែលអាចចូលប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន ស្របទៅតាមកថាខ័ណ្ឌទី ៧ នៃ មាត្រា ៣៨ អំពីការកែសម្រួល ការបញ្ចូលបន្ថែមការកែតម្រូវ ឬការលុបចេញទាំងនោះ។

៣. ប្រសិនបើភាគីហត្ថលេខី មានព័ត៌មានស្នើសុំទិន្នន័យផ្ទាល់ខ្លួនមិនត្រឹមត្រូវ ឬត្រូវបានបញ្ចូលឬ ស្តុកនៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្វ័យប្រវត្តិកម្មដែលផ្ទុយនឹងអនុសញ្ញានេះ ត្រូវធ្វើការផ្តល់យោបល់ដល់ភាគីហត្ថលេខីដែលផ្តល់ព័ត៌មានបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន។ បន្ទាប់មកត្រួតពិនិត្យទិន្នន័យដែលពាក់ព័ន្ធ ហើយបើសិនចាំបាច់រៀបចំការកែសម្រួល បញ្ចូលបន្ថែម កែតម្រូវ ឬលុបចេញដោយគ្មានការយឺតយ៉ាវ។ ភាគីហត្ថលេខីផ្តល់ព័ត៌មាន ត្រូវរៀបចំជាមួយអគ្គលេខាធិការ ដើម្បីជូនដំណឹងដល់ភាគីដែលអាចចូលប្រើព័ត៌មានទិន្នន័យផ្ទាល់ខ្លួន ស្របតាមកថាខ័ណ្ឌទី ៧ នៃមាត្រា ៣៨ អំពីការកែសម្រួលការបញ្ចូលបន្ថែម ការកែតម្រូវ ឬការលុបចេញទាំងនោះ។

៤. ប្រសិនបើនៅពេលបញ្ចូលទិន្នន័យផ្ទាល់ខ្លួន នៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម ភាគីហត្ថលេខីទទួលស្គាល់ថាទិន្នន័យផ្ទាល់ខ្លួនរបស់ខ្លួនខុសពីទិន្នន័យផ្ទាល់ខ្លួន ដែលផ្តល់ដោយពីភាគីហត្ថលេខីផ្សេងទៀត ត្រូវធ្វើការឱ្យយោបល់ដល់ភាគីហត្ថលេខីភ្លាមអំពីទិន្នន័យបានអ្នកផ្តល់ឱ្យនោះ។ភាគីហត្ថលេខីពាក់ព័ន្ធ ត្រូវព្យាយាមដោះស្រាយបញ្ហា។ បើសិនការដោះស្រាយបញ្ហាផ្តល់លទ្ធផលក្នុងការកែសំរួល ការបញ្ចូលបន្ថែម ការកែតំរូវ ឬការលុបចេញនូវទិន្នន័យផ្ទាល់ខ្លួនភាគីហត្ថលេខីដែលផ្តល់នូវទិន្នន័យនោះជាមួយអគ្គលេខាធិការត្រូវជូនដំណឹងដល់ ភាគីដែលអាចចូលប្រើព័ត៌មានទិន្នន័យផ្ទាល់ខ្លួន តាមស្របទាមកថាខ័ណ្ឌទី ៧ មាត្រា ៣៨ អំពី ការកែសំរួល ការបញ្ចូលបន្ថែម ការកែតំរូវ ឬការលុបចោលទាំងនោះ។

៥. នៅពេលតុលាការ ឬនៅអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត នៅក្នុងដែនដីភាគីហត្ថលេខីធ្វើការសំរេចចិត្តចុងក្រោយ ដែលពាក់ព័ន្ធដល់ការកែសំរួលការបញ្ចូលបន្ថែម ការកែតំរូវ ឬការលុបចេញនូវទិន្នន័យផ្ទាល់ខ្លួនក្នុងមជ្ឈមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មនៅក្នុងដែនដីភាគីហត្ថលេខីដែលបានធ្វើការសំរេចចិត្ត ត្រូវរៀបចំធ្វើការកែសំរួល ការបញ្ចូលបន្ថែម ការកែតំរូវ ឬការលុបចេញដោយគ្មានគ្មានការយឺតយ៉ាវ ឬបើទិន្នន័យដែលបានផ្តល់ឱ្យដោយ ភាគីហត្ថលេខីផ្សេងទៀត ត្រូវអោយយោបល់ដល់ភាគីហត្ថលេខីដែលបានផ្តល់ពត៌មានពីការសំរេចចិត្ត។ ភាគីហត្ថលេខីដែលផ្តល់ទិន្នន័យ ត្រូវរៀបចំកែសំរួលបញ្ចូលបន្ថែម កែតំរូវឬលុបចេញនូវទិន្នន័យទាំងនោះដោយគ្មានការយឺតយ៉ាវ។

## មាត្រា ៤១

## ការទទួលខុសត្រូវ

១. ភាគីហត្ថលេខី ត្រូវទទួលខុសត្រូវ តាមលទ្ធភាពដែលអាចទទួលយកបានចំពោះភាពត្រឹមត្រូវ រូបិយប័ណ្ណ និងភាពស្របច្បាប់នៃព័ត៌មានដែលបានបញ្ចូលក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម។

២. ភាគីហត្ថលេខី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ស្របតាមបញ្ញត្តិច្បាប់ និងវដ្តបាលរបស់ខ្លួនចំពោះការខូចខាតដល់ពីបុគ្គលតាមរយៈការប្រើប្រាស់នូវព័ត៌មានវ៉

ផលទទួលបានពីមជ្ឈមណ្ឌល ប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មដោយភាគីហត្ថលេខីនោះ។ នេះ គឺជាករណីខូចខាតដែលបណ្តាល មកពីភាគីហត្ថលេខីដែលជាអ្នកផ្តល់បញ្ចូលនូវទិន្នន័យដែលមិនត្រឹមត្រូវ ឬបញ្ចូលនូវទិន្នន័យដែលផ្ទុយពីអនុសញ្ញានេះ ។

៣. ប្រសិនបើភាគីហត្ថលេខី រកឃើញថាត្រូវទទួលខុសត្រូវចំពោះការខូចខាតស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ មិនមែនជាភាគីហត្ថលេខីដែលផ្តល់នូវព័ត៌មាននោះ ភាគីហត្ថលេខីទាំងអស់ពាក់ព័ន្ធ ត្រូវយល់ព្រមតាមល័ក្ខខ័ណ្ឌនៃសំណងចំពោះភាគីហត្ថលេខីដែលទទួលខុស ត្រូវនូវចំនួនទឹកប្រាក់ដែលត្រូវសងជំងឺចិត្ត។

៤. ភាគីហត្ថលេខី ត្រូវទទួលខុសត្រូវស្របតាមបញ្ញត្តិច្បាប់ និងរដ្ឋបាលរបស់ខ្លួនចំពោះការខូច ខាតដល់បុគ្គល តាមរយៈការប្រើប្រាស់នូវព័ត៌មានដោយមន្ត្រីក្រុមប្រឹក្សាដែលទទួលបានពីមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មដែលផ្ទុយពីអនុសញ្ញានេះ តាមទំហំនៃព័ត៌មានដែលត្រូវបញ្ចូលនៅក្នុងប្រព័ន្ធដោយភាគីហត្ថលេខីនោះ ។

៥. ប្រសិនបើ ការខូចខាតបង្កឡើងដោយអាជ្ញាធរតុលាការមានសមត្ថកិច្ច ដោយអនុលោមតាមកថាខណ្ឌទី ៤ នៃមាត្រានេះ ភាគីហត្ថលេខីពាក់ព័ន្ធ អាចពឹងផ្អែកលើការសំរេចចិត្តរបស់គណៈ កម្មាធិការរដ្ឋបាល ថាតើនរណាខ្លះដែលនឹងត្រូវផ្តល់អនុសាសន៍ឱ្យក្រុមប្រឹក្សាអំពីសំណងណាមួយ។

## ជំពូក ១១
## ការលើកលែង និង ការបំរុងទុក
### មាត្រា ៤២
### ការលើកលែង

១. នៅពេលមានសំណើជំនួយណាមួយក្រោមអនុសញ្ញានេះ អាចរំលោភដល់អធិបតេយ្យភាពច្បាប់ និងកាតព្វកិច្ចសន្ធិសញ្ញា សន្តិសុខ គោលនយោបាយសាធារណៈ ឬផលប្រយោជន៍ជាតិដ៏មាន សារៈសំខាន់ផ្សេងទៀតរបស់ភាគីហត្ថលេខី

ទទួលការស្នើសុំនោះ ឬក៏ធ្វើឱ្យខូចខាតដល់ផល ប្រយោជន៍ពាណិជ្ជកម្មស្រប ច្បាប់និងវិជ្ជាជីវៈណាមួយ ការសុំជំនួយបែបនោះ អាចត្រូវបានបដិសេធដោយ ភាគីហត្ថលេខីនោះ ហើយត្រូវផ្តល់អោយដោយល័ក្ខខ័ណ្ឌណាមួយ។

២. នៅពេលរដ្ឋបាលស្នើសុំ មិនអាចឆ្លើយតបទៅ ប្រសិនបើមានសំណើប្រហាក់ ប្រហែលគ្នាពីរដ្ឋបាលទទួលសំណើ ត្រូវយកចិត្តទុកដាក់លើការពិតក្នុងសំណើ របស់ខ្លួន។ តាមសំណើមួយបែបនោះត្រូវសំរេចដោយរដ្ឋបាលទទួលការស្នើសុំ។

៣. ជំនួយអាចត្រូវបានគេពន្យា ប្រសិនបើមានហេតុផលជាច្រើនដែលគេជឿថា វា មានការពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេត បណ្តឹងសាធារណៈ ឬរឿងក្តី។ ក្នុង ករណីបែបនេះ រដ្ឋបាលទទួលសំណើ ត្រូវពិគ្រោះយោបល់ជាមួយរដ្ឋបាល ស្នើសុំ ដើម្បីពិនិត្យថាតើត្រូវផ្តល់ជំនួយឬអត់តាមល័ក្ខខ័ណ្ឌកំណត់ដោយរដ្ឋបាល ទទួលការស្នើសុំ។

៤. ប្រសិនបើរដ្ឋបាលទទួលសំណើពិចារណាថា ការខិតខំបំពេញនូវសំណើមួយគឺពុំ សមមាត្រទាល់តែសោះទៅនឹងផលប្រយោជន៍ដែលរដ្ឋបាលស្នើសុំត្រូវទទួលនោះ រដ្ឋបាលទទួលសំណើ អាចធ្វើការបដិសេធការជំនួយដែលបានស្នើនោះ។

៥. នៅពេលការផ្តល់ជំនួយត្រូវបានបដិសេធឬពន្យាពេល ត្រូវធ្វើការបញ្ជាក់ហេតុ ផលនៃការបដិសេធ ឬការពន្យាពេលនោះ ។

## មាត្រា ៤៣
## ការត្រៀមបំរុង

១. មាត្រា ៩, ១០, ១២, ១៤, ១៥, ១៦, ១៧, ១៩, ២០, ២១, ២២, ២៣, ២៩ និង ៣០ អាចជាបញ្ញត្តិត្រៀមបំរុងទាំងស្រុង ឬជាផ្នែក។

២. ភាគីហត្ថលេខីមួយ ត្រូវបានគេគិតថាអាចទទួលយកបទបញ្ញត្តិទាំងអស់ក្នុង មាត្រា ៩, ១០, ១២, ១៤, ១៥, ១៦, ១៧, ១៩, ២០, ២១, ២២, ២៣, ២៩ និង ៣០ តែបើមិនអាចទទួលយកនៅពេលចុះហត្ថលេខា សច្ចានុមតិឬការចូលជាសមាជិកនៃអនុសញ្ញានេះទេ ត្រូវជូនដំណឹងទៅអគ្គ

លេខាធិការ អំពីបទបញ្ញត្តិត្រៀមបំរុងណាខ្លះដោយអនុលោមតាមបទបញ្ញត្តិទាំងអស់នេះ។

៣. ភាគីហត្ថលេខីមួយ ដែលបានត្រៀមបំរុងនូវបទបញ្ញតិមួយចំនួន អាចដកចេញវិញទាំងស្រុង ឬជាផ្នែកគ្រប់ពេលទាំងអស់ ដោយសេចក្តីជូនដំណឹងទៅអ្នកតំកល់ទុកព្រមទាំងបញ្ជាក់កាលបរិច្ឆេទចូលជាធរមាននៃការដកនោះ។

## ជំពូក ១២

## ការចំណាយ

### មាត្រា ៤៤

១. ផ្អែកលើកថាខ័ណ្ឌទី ២ និង ៣ នៃមាត្រានេះ ចំណាយបានកើតឡើងនៅក្នុងការអនុវត្តនៃអនុសញ្ញានេះ ត្រូវជាបន្ទុករបស់ភាគីហត្ថលេខីទទួលការស្នើសុំ។

២. ការចំណាយ និងវិភាជន៍ផ្សេងៗ ដែលត្រូវបង់ទៅឱ្យអ្នកជំនាញការ និងសាក្សីផ្សេងៗព្រមទាំង ថ្លៃអ្នកបកប្រែឯកសារ និងអ្នកបកប្រែផ្ទាល់មាត់ ក្រៅពីនិយោជិតរដ្ឋាភិបាល ត្រូវជាបន្ទុករបស់ភាគីហត្ថលេខីស្នើសុំ។

៣. ប្រសិនបើការប្រតិបត្តិនៃសំណើ ទាមទារឱ្យមានការចំណាយជាទ្រង់ទ្រាយធំ និងវិសាមញ្ញ ភាគីហត្ថលេខីទាំងអស់ ត្រូវពិគ្រោះយោបល់ដើម្បីពិនិត្យលើល័ក្ខខ័ណ្ឌដែលត្រូវអនុវត្តសំណើព្រមទាំងបន្ទុកចំណាយ។

## ជំពូក ១៣

## អវសានបញ្ញត្តិ

### មាត្រា ៤៥

### ការគ្រប់គ្រងនៃអនុសញ្ញា

១. គណៈកម្មាធិការរដ្ឋបាល ត្រូវគេបង្កើតដើម្បី :

ក- ពិនិត្យពិចារណាបញ្ហាទាំងឡាយដែលទាក់ទងនឹងការអនុវត្ត និងការគ្រប់គ្រងអនុសញ្ញា និងរាល់ការធ្វើវិសោធនកម្មដែលលើកឡើងទាក់ទងនឹងអនុសញ្ញា

នេះ។

ខ- ផ្តល់អនុសាសន៍ជូនភាគីហត្ថលេខានូវវិសោធនកម្មអនុសញ្ញានេះ។

គ- ផ្តល់អនុសាសន៍ដល់ភាគីហត្ថលេខី ដើម្បីចាត់វិធានការនានា ជានាដល់បំណកស្រាយ និងការអនុវត្តឱ្យមានការឯកភាពគ្នា។

ឃ- ធ្វើការសំរេចនូវសមាសភាពក្រុមអ្នកគ្រប់គ្រង ស្របទៅតាមកថាខ័ណ្ឌទី ១ មាត្រា ៣២។

ង- ត្រួតពិនិត្យ និងអនុម័តនីតិវិធីប្រតិបត្តិនិងបច្ចេកទេស ស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ៣២ ដែលទាក់ទងនឹងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្ម។

ច- តែងតាំងអ្នកតំណាងឯករាជ្យម្នាក់ឬច្រើននាក់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ស្របតាមកថាខ័ណ្ឌទី ២ មាត្រា ៣៣ និងកថាខ័ណ្ឌទី ៤ មាត្រា ៣៧ និងកំណត់ពីទំហំ ភាពញឹកញាប់ និង ល័ក្ខខ័ណ្ឌផ្សេងៗ សំរាប់ការផ្ទៀងផ្ទាត់ទាំងនេះ។

ឆ- កំណត់លក្ខ័ខ័ណ្ឌផ្សេងៗស្របតាមទៅនឹងកថាខ័ណ្ឌទី ៣ នៃមាត្រា ៣៦ ដែលទាក់ទងនឹងការ ប្រើប្រាស់ព័ត៌មានដែលទទួលបានពីពីមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិកម្មរបស់មន្ត្រីក្រុមប្រឹក្សា។

ជ- កំណត់ល័ក្ខខ័ណ្ឌផ្សេងៗ ស្របទៅនឹងកថាខ័ណ្ឌទី ៤ មាត្រា ៣៨ ដែលទាក់ទងនឹងការផ្តល់សិទ្ធិឱ្យប្រើប្រាស់ព័ត៌មានមិនផ្ទាល់ខ្លួន ដែលមាននៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានស្វ័យ ប្រវត្តិកម្មតាមរយៈអង្គការចាត់តាំងរបស់រដ្ឋាភិបាលតាមតំបន់ និងអន្តរជាតិ។

ឈ- ផ្តល់អនុសាសន៍ទៅឱ្យក្រុមប្រឹក្សាចំពោះការទូទាត់សងត្រលប់មកវិញ ស្របតាមកថាខ័ណ្ឌទី ៥ នៃមាត្រា ៤១ ។

ញ- រក្សាទំនាក់ទំនងជាមួយអង្គការចាត់តាំងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ ។

ដ- ពិនិត្យពិច័យរាល់បណ្តាបញ្ហាៗទៀតដែលទាក់ទិននឹងអនុសញ្ញានេះ។

ផ- ផ្តល់គំហើងដល់គណៈកម្មាធិការអនុវត្តច្បាប់និងក្រុមប្រឹក្សា នូវរាល់សេចក្តីសំរេចរបស់ខ្លួន។

២. គណៈកម្មាធិការរដ្ឋបាល ត្រូវយកសេចក្តីសំរេចទាំងឡាយ ដែលទាក់ទងនឹងការផ្លាស់ប្តូរបញ្ជីឈ្មោះ ដូចមានក្នុងមាត្រា ១០, ២៨ និង ២៩ ដោយមិនអាស្រ័យលើមាត្រា ៤៩ ទាក់ទងទៅនឹងការអនុវត្តសេចក្តីសំរេចទាំងនេះ។

៣. ភាគីហត្ថលេខីទាំងអស់នៅក្នុងអនុសញ្ញានេះ ត្រូវជាសមាជិករបស់គណៈកម្មាធិការរដ្ឋបាល។

៤. អង្គភាពដែលមានលក្ខណៈសម្បត្តិអាចទៅជាភាគីហត្ថលេខី នៃអនុសញ្ញានេះ ក្នុងបទបញ្ញត្តិនៃមាត្រា ៤៦ អាចត្រូវបានញើញឱ្យចូលរួមសម័យប្រជុំរបស់គណៈកម្មាធិការរដ្ឋបាលជាអ្នកសង្កេតការ។ ឋានៈ និងសិទ្ធិរបស់អ្នកសង្កេតការនេះ ត្រូវបានកំណត់ដោយគណៈកម្មាធិការរដ្ឋបាល។ គណៈកម្មាធិការរដ្ឋបាលនេះ អាចកោះអញ្ជើញអ្នកតំណាងពីអង្គការអន្តរជាតិឱ្យចូលរួមសម័យប្រជុំរបស់ខ្លួនជាអ្នកសង្កេតការផងដែរ។

៥. គណៈកម្មាធិការរដ្ឋបាល ត្រូវបង្កើតនីតិវិធីច្បាប់ដោយសំលេងភាគច្រើន គឺមិនតិចជាងពីរភាគបីនៃភាគីហត្ថលេខីនៃអនុសញ្ញា។ នៅពេលដែលអនុសញ្ញានេះបានចូលជាធរមានតែពុំមាន នីតិវិធីច្បាប់របស់គណៈកម្មាធិការរដ្ឋបាលនោះ នីតិវិធីច្បាប់របស់ក្រុមប្រឹក្សាអាចត្រូវយកមកអនុវត្តរហូតទាល់តែគណៈកម្មាធិការរដ្ឋបាលនេះអនុម័តនីតិវិធីរបស់ខ្លួន។

៦. ដោយមិនប៉ះពាល់ដល់កថាខ័ណ្ឌទី ៥ នៃមាត្រានេះ កិច្ចការទាក់ទងទៅនឹងអនុសញ្ញានេះ មុនពេលគណៈកម្មាធិការរដ្ឋបាល ត្រូវបានសំរេចដោយការឯកភាពនៃអ្នកដែលមានវត្តមានចូលរួមទាំងអស់នោះ។ ប្រសិនបើការសំរេចមិនអាចឈានដល់ការព្រមព្រៀងរួមទេ បញ្ហានេះត្រូវសំរេចតាមវិធីយ៉ាងងាយដោយសំលេងភាគច្រើនរបស់អ្នកចូលរួមទាំងអស់នោះ។ ទោះជាយ៉ាងណាក៏ដោយគោលបំណងនៃការកែប្រែបញ្ជីនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១០ កថាខ័ណ្ឌទី ១ នៃមាត្រា ២៨ កថាខ័ណ្ឌទី ១ នៃមាត្រា ២៩ និងគោលបំណងនៃការតែងតាំងអ្នកតំណាងម្នាក់ ឬច្រើនស្របតាមកថខ័ណ្ឌទី ១ នៃ

មាត្រា ១(ច) នៃមាត្រានេះ ការសំរេចត្រូវធ្វើឡើងដោយសំលេងភាគច្រើនមិនតិចជាងពីរភាគបីនៃភាគីហត្ថលេខីទាំងអស់ដែលបានចូលរួម ហើយជាអ្នកដែលមានសិទ្ធិបញ្ចេញសំលេង។ ក្នុងករណីការផ្តល់សិទ្ធិឱ្យប្រើព័ត៌មានមិនផ្ទាល់ខ្លួនស្របតាមកថាខ័ណ្ឌទី ៤ នៃមាត្រា ៣៨ ការសំរេចត្រូវធ្វើឡើងដោយសំលេងឯកច្ឆ័ន្ទរបស់អ្នកចូលរួមទាំងនោះ។

៧. ភាគីហត្ថលេខីនីមួយៗ អាចមានសិទ្ធិបោះឆ្នោតមួយសំលេង។ តាមកថាខ័ណ្ឌទី ៣ និងទី ៤ នៃ មាត្រា ៤៦ សហភាពសេដ្ឋកិច្ចដែលជាភាគីហត្ថលេខីក្នុងករណីមានការបោះឆ្នោត គេអាចមានសំលេងត្រឹមតែមួយគត់ដែលស្មើនឹងសំលេងសរុប ដែលបែងចែកទៅឱ្យសមាជិករបស់ពួកគេដែលជាភាគីហត្ថលេខី។

៨. គណៈកម្មាធិការរដ្ឋបាល ត្រូវធ្វើការជួបប្រជុំគ្នាយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ កិច្ចប្រជុំនេះ អាចនឹងជ្រើសរើសប្រធាន និងអនុប្រធានជារៀងរាល់ឆ្នាំ។ រដ្ឋបាលគយរបស់ភាគីហត្ថលេខី ត្រូវទាក់ទងជាមួយនឹងអគ្គលេខាធិការនូវការស្នើសុំបញ្ចូលរបៀបវារៈកិច្ចប្រជុំរបស់គណៈកម្មការរដ្ឋបាល។ អគ្គលេខាធិការត្រូវបញ្ជូនលិខិតអញ្ជើញ និងសេចក្តីព្រាងរបៀបវារៈទៅកាន់ រដ្ឋបាលគយទាំងអស់នៃភាគីហត្ថលេខី និងអ្នកសង្កេតការ ស្របតាមកថាខ័ណ្ឌ ៤ នៃមាត្រានេះអោយបាន ៦ សប្តាហ៍ មុននឹងមានការប្រជុំរបស់គណៈកម្មាធិការរដ្ឋបាល។

៩. ក្រុមប្រឹក្សានេះ ត្រូវផ្តល់ឱ្យគណៈកម្មាធិការរដ្ឋបាលនូវសេវាលេខាធិការដ្ឋាន។

## មាត្រា ៤៦
## ហត្ថលេខា សច្ចានុមតិ និងការចូលជាសមាជិក

១. រាល់សមាជិកនៃក្រុមប្រឹក្សា និងសមាជិករបស់អង្គការសហប្រជាជាតិ ឬក៏ទីភ្នាក់ងារដែលមានឯកទេសផ្សេងៗអាចក្លាយជាភាគីហត្ថលេខីនៃអនុសញ្ញានេះ :

ក- ដោយការចុះហត្ថលេខាដោយមិនមានការត្រៀមបំរុងនៃសច្ចានុមតិ

ខ- ដោយការតំកល់នូវលិខិតូបករណ៍នៃសច្ចានុមតិ បន្ទាប់ពីបានចុះហត្ថលេខារួចចំពោះសច្ចានុមតិនោះ ឬ

គ- ដោយការចូលជាសមាជិកនៃអនុសញ្ញានេះ

២. អនុសញ្ញានេះ ត្រូវគេបើកអោយចុះហត្ថលេខារហូតដល់ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០០៤ នៅអគ្គលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សានេះនៅទីក្រុងប្រ៊ូសែល តាមរយៈសមាជិក នៃក្រុមប្រឹក្សា នេះស្របតាមកថាខ័ណ្ឌទី ១ នៃមាត្រានេះ។ បន្ទាប់មក ត្រូវបើកអោយសុំចូលជាសមាជិកតាម រយៈសមាជិកភាពទាំនោះ។

៣. សហភាពគយ ឬសហភាពសេដ្ឋកិច្ច អាចក្លាយជាភាគីហត្ថលេខីនៃអនុសញ្ញា នេះ ស្របទៅតាមកថាខ័ណ្ឌទី ១ និង ២ នៃមាត្រានេះ។ សហភាពគយ ឬសហភាពសេដ្ឋកិច្ចទាំងនោះ ត្រូវជំរាបជូនទៅអគ្គលេខាធិការ អំពីសមាជិក ដែលបានបង្កើតជាសហភាពនោះ រួមទាំងសមត្ថកិច្ចរបស់ខ្លួនចំពោះកិច្ចការទាំង ឡាយស្ថិតក្រោមអនុសញ្ញានេះផងដែរ។ សហភាពគយ ឬសហភាពសេដ្ឋកិច្ច ទាំងនេះ ត្រូវតែជំរាបទៅអគ្គលេខាធិការអំពីការកែប្រែបន្ថែមនៅក្នុងវិសាលភាព នៃសមត្ថកិច្ចរបស់ខ្លួននេះ។

៤. ចំពោះកិច្ចការស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន សហភាពគយឬសហភាពសេដ្ឋកិច្ច ជាភាគីហត្ថលេខីនៃអនុសញ្ញានេះត្រូវអនុវត្តសិទ្ធិរបស់ខ្លួន បំពេញរាល់ការទទួល ខុសត្រូវដែលអនុសញ្ញា នេះប្រគល់អោយជាសមាជិកនៃសហភាព និងជាភាគី ហត្ថលេខីនៃអនុសញ្ញានេះ។ ក្នុងករណីនេះ សមាជិកនៃសហភាពទាំងនោះគ្មាន សិទ្ធិអនុវត្តដោយបុគ្គលនូវសិទ្ធទាំនោះទេ រួមទាំងសិទ្ធបោះឆ្នោតផង។

៥. រាល់ភាគីហត្ថលេខីដែលបានផ្តល់សច្ចានុម័ត ឬក៏ចូលជាសមាជិកនេះ ត្រូវបាន ចងដោយការធ្វើវិសោធនកម្មអនុសញ្ញានេះ ដែលចូលជាធរមាននៅថ្ងៃដាក់ លិខិតុបករណ៍នៃការធ្វើសច្ចានុម័តចូលជាសមាជិកតែម្តង។

## មាត្រា ៤៧

## ដែនដីអនុវត្តនៃអនុសញ្ញា

១. ភាគីហត្ថលេខី អាចប្រកាសគ្រប់ពេលទាំងអស់ដោយការជូនដំណឹងដល់អ្នក តំកល់ទុកនៃអនុសញ្ញានេះ ត្រូវពង្រីកវិសាលភាពទៅគ្រប់ឬដែនដីណាមួយរបស់ ខ្លួនសំរាប់ទំនាក់ទំនងអន្តរជាតិរបស់គេដែលអនុសញ្ញានេះទទួលខុសត្រូវ។

សេចក្ដីជូនដំណឹងនេះ នឹងមានប្រសិទ្ធភាពបីខែបន្ទាប់ពីកាលបរិច្ឆេទទទួលការប្រកាសនោះ។ ទោះបីជាយ៉ាងណាក៏ដោយអនុសញ្ញានេះ មិនអាចប្រើបានគ្រប់ដែនដីដែលមានឈ្មោះនៅក្នុងសេចក្ដីជូនដំណឹងមុនពេលអនុសញ្ញានេះ ចូលជាធរមានបានទេសំរាប់ភាគីហត្ថលេខីដែលពាក់ព័ន្ធ។

២. ភាគីហត្ថលេខីដែលបានជូនដំណឹងនៅក្នុងកថាខ័ណ្ឌទី ១ ខាងលើនៃមាត្រានេះ ការពង្រីកវិសាលភាពអនុសញ្ញានេះទៅដល់ដែនដីណាមួយ សំរាប់ទំនាក់ទំនងរបស់គេដែលអនុសញ្ញានេះទទួលខុសត្រូវ អាចជូនដំណឹងដល់អ្នកតំកល់ទុកថាដែនដីពាក់ព័ន្ធនេះមិនអាចអនុវត្តបានទៀតទេ តាមនីតិវិធីនៃមាត្រា ៥២ នៃអនុសញ្ញានេះ។

## មាត្រា ៤៨
## អនុវត្តន៍នៃអនុសញ្ញា

១. ក្នុងការអនុវត្តអនុសញ្ញានេះ ភាគីហត្ថលេខី តាមលទ្ធភាពដែលអាចធ្វើបាន ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាថា មន្ត្រីរបស់គេដែលជាអ្នកទទួលខុសត្រូវក្នុងការស៊ើបអង្កេតឬបង្ក្រាបរាល់បទល្មើសគយ ដោយរក្សាទំនាក់ទំនងផ្ទាល់ខ្លួនទៅវិញទៅមកជាមួយគ្នា។

២. ភាគីហត្ថលេខីពីរឬច្រើន អាចធ្វើការសំរេចចិត្តលើកិច្ចព្រមព្រៀងទៅវិញទៅមក ដើម្បីសម្របសម្រួលដល់ការអនុវត្តន៍និងការស្នើសុំរវាងពួកគេ។

## មាត្រា ៤៩
## វិសោធនកម្មលើអនុសញ្ញា

១. អត្ថបទនៃវិសោធនកម្មណាមួយ បានផ្ដល់អនុសាសន៍ដល់ភាគីហត្ថលេខីដោយគណៈកម្មាធិការរដ្ឋបាល ដូចមានចែងក្នុងកថាខ័ណ្ឌទី ១(ខ)នៃមាត្រា ៤៥ ត្រូវធ្វើការទាក់ទងតាមរយៈអគ្គលេខាធិការដល់គ្រប់ភាគីហត្ថលេខី និងសមាជិកនៃក្រុមប្រឹក្សានេះដែលមិនមែនជាភាគីហត្ថលេខី។

២. ការស្នើសុំធ្វើវិសោធនកម្មលើអនុសញ្ញានេះ ត្រូវចូលជាធរមានក្នុងរយៈពេលបីខែ បន្ទាប់ពីផុតកំណត់រយៈពេល ២៤ខែ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការធ្វើទំនាក់ទំនងស្នើសុំធ្វើវិសោធនកម្ម ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ បើសិនគ្មានការជំទាស់ចំពោះការស្នើសុំធ្វើ វិសោធនកម្មត្រូវបានធ្វើការទាក់ទងដោយភាគីហត្ថលេខីមួយទៅអគ្គលេខាធិការក្នុងកំឡុងពេលនោះទេ។

៣. ប្រសិនបើមានការជំទាស់ណាមួយចំពោះការស្នើសុំធ្វើវិសោធនកម្ម ដែលបានដាក់ជូនដោយភាគីហត្ថលេខី មុនកាលបរិច្ឆេទផុតកំណត់ ២៤ខែ ដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌទី ២ នៃមាត្រានេះ ការធ្វើវិសោធនកម្មនេះត្រូវគេចាត់ទុកថាមិនមានការយល់ព្រម។

## មាត្រា ៥០
## ដំណោះស្រាយវិវាទ

១. ដោយមិនមានការប៉ះពាល់ដល់កថាខ័ណ្ឌទី ១(គ) នៃមាត្រា ៤៥ រាល់វិវាទរវាងរដ្ឋបាលគយពីរឬច្រើនដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍នូវអនុសញ្ញានេះ ត្រូវដោះស្រាយតាមរយៈការចរចារគ្នាតាមលទ្ធភាពដែលបានធ្វើទៅបាន។

២. រាល់វិវាទដែលមិនអាចដោះស្រាយបានតាមរយៈការចរចារដោយភាគីហត្ថលេខី ត្រូវបញ្ជូនទៅគណៈកម្មាធិការរដ្ឋបាលដែលត្រូវពិចារណានូវវិវាទនោះ ហើយផ្តល់អនុសាសន៍សំរាប់ដំណោះស្រាយ។

៣. ភាគីហត្ថលេខីដែលមានវិវាទគ្នានោះអាចយល់ព្រមជាមុន ក្នុងការទទួលយកអនុសាសន៍របស់គណៈកម្មាធិការរដ្ឋបាលដូចមានចែង។

៤. រាល់វិវាទដែលមិនមានដំណោះស្រាយ ត្រូវគេដោះស្រាយតាមរយៈការទូត។

## មាត្រា ៥១

## ការចូលជាធរមាន

១. អនុសញ្ញានេះ ត្រូវចូលជាធរមានក្នុងរយៈពេលបីខែបន្ទាប់ពីមានសមាជិកចំនួនប្រាំបានចូល យោងតាមកថាខ័ណ្ឌទី ១ និង ៣ នៃមាត្រា ៤៦ ដែលបានចុះហត្ថលេខានៅលើអនុសញ្ញានេះ ដោយគ្មានបំរុងទុកនៃសច្ចានុមតិ ឬក៏បានដាក់តំកល់នូវលិខិតុបករណ៍នៃសេចក្តីជូនដំណឹងឬការចូលជាសមាជិក។

២. បន្ទាប់ពីចូលជាធរមាន ដូចមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះអនុសញ្ញានេះ ត្រូវចូលជាធរមានសំរាប់ភាគីហត្ថលេខីណាមួយផ្សេងទៀតក្នុងរយៈពេលបីខែបន្ទាប់ពីវាក្លាយជាភាគីហត្ថលេខីដែលស្របតាមបញ្ញត្តិនៃមាត្រា ៤៦។

## មាត្រា ៥២

## ការដំទាស់

១. អនុសញ្ញានេះមិនកំណត់រយៈពេល ប៉ុន្តែភាគីហត្ថលេខីណាមួយអាចជំទាស់បានគ្រប់ពេលបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមានរបស់វាអនុលោមតាមមាត្រា៥១។

២. ការជំទាស់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរចំពោះអ្នកតំកល់ទុកនៅអ្នកតំកល់ទុក ។

៣. ការជំទាស់មានប្រសិទ្ធិភាពរយៈពេល ៦ខែ បន្ទាប់ពីទទួលលិខិតុបករណ៍ជំទាស់ដោយអ្នកតំកល់ទុក។

## មាត្រា ៥៣

## ការតំកល់នៃអនុសញ្ញា

១. អនុសញ្ញានេះ រាល់ហត្ថលេខាទាំងអស់ទោះជាមាន ឬគ្មានការត្រៀមបំរុងនៃសច្ចានុមតិក៏ដោយ និងលិខិតុបករណ៍នៃសច្ចានុមតិឬការចូលជាសមាជិក ត្រូវតំកល់នៅអគ្គលេខាធិការ។

២. អ្នកតំកល់ទុកត្រូវ :

ក. ទទួល និងថែរក្សាទុកអត្ថបទដើមនៃអនុសញ្ញានេះ

ខ. រៀបចំច្បាប់ថតចំលងនៃអត្ថបទដើមនៃអនុសញ្ញា ហើយចែកជូនទៅភាគីហត្ថលេខីទាំងអស់ និងគ្រប់សមាជិកនៃក្រុមប្រឹក្សាដែលមិនមែនជាភាគីហត្ថលេខី និងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

គ. ទទួលរាល់ហត្ថលេខា ទោះមានឬគ្មានការត្រៀមបំរុងនៃសច្ចានុមតិ សច្ចានុមតិឬការចូលជាសមាជិកនៃអនុសញ្ញានេះ និង ទទួលនិងរក្សាទុកលិខិតុបករណ៍ សេចក្តីជូនដំណឹង និងការទំនាក់ទំនងជាមួយអនុសញ្ញានេះ។

ឃ. ទទួល និងរក្សាទុកនូវច្បាប់ជាតិនិងបទបញ្ញត្តិរដ្ឋបាល និងការប្រកាសជាលាយលក្ខណ៍អក្សរដោយយោងតាមកថាខ័ណ្ឌទី ៤ នៃមាត្រា ២៥។

ង. ទទួលនិងរក្សាទុកការ សេចក្តីជូនដំណឹងនៃការបំរុងទុកដោយភាគីហត្ថលេខីស្របតាមមាត្រា ៤៣។

ច. ត្រួតពិនិត្យមើលហត្ថលេខាឬលិខិតុបករណ៍ សេចក្តីជូនដំណឹងនិងការទំនាក់ទំនងជាមួយអនុសញ្ញានេះដែលមានទំរង់សមស្របនិងត្រឹមត្រូវនិងលើកបញ្ហាចំណាប់អារម្មណ៍ដល់ភាគីហត្ថលេខីដែលពាក់ព័ន្ធ។

ឆ. ជូនដំណឹងដល់ភាគីហត្ថលេខីទាំងអស់ សមាជិកនៃក្រុមប្រឹក្សាទាំងឡាយដែលមិនមែនជាភាគីហត្ថលេខី និងអគ្គលេខាធិការអង្គការសហប្រជាជាតិអំពីៈ

- កាលបរិច្ឆេទ នៃការចូលជាធរមានអនុសញ្ញានេះ ស្របមាត្រា ៥១ នៃអនុសញ្ញានេះ
- សេចក្តីជូនដំណឹងដែលបានទទួល យោងតាមមាត្រា ៤៣, ៤៦, ៤៧ និង ៥១ នៃ អនុសញ្ញានេះ
- ការជំទាស់ យោងតាមមាត្រា ៥២ នៃអនុសញ្ញានេះ
- ការយល់ព្រមឬជំទាស់លើវិសោធនកម្ម យោងតាមមាត្រា៤៩ នៃអនុសញ្ញានេះ និងកាលបរិច្ឆេទចូលជាធរមាន។
- ការសំរេចដោយគណៈកម្មាធិការរដ្ឋបាល យោងតាមកថាខ័ណ្ឌ២នៃមាត្រា ៤៥។

ជ. ជូនដំណឹងដល់ភាគីហត្ថលេខីនៃអាជ្ញាធរ យោងតាមកថាខ័ណ្ឌ ៣ នៃមាត្រា ២ ។

ឈ. ផ្ដូនដំណឹងដល់ទំនងរដ្ឋបាលគយនៃមន្ត្រីទំនាក់ទំនង យោងតាមកថាខ័ណ្ឌទី១ នៃមាត្រា ៣។

៣. ក្នុងករណីកើតឡើងនូវហេតុការខុសគ្នារវាងភាគីហត្ថលេខី និងអ្នកតំកល់ទុក ចំពោះការបំពេញនៃមុខងារជាបន្តបន្ទាប់អ្នកតំកល់ទុក ឬភាគីហត្ថលេខីត្រូវលើកបញ្ហាដើម្បីជាការចាប់អារម្មណ៍ ដល់ភាគីហត្ថលេខីដទៃទៀត និងដល់ហត្ថលេខីនិងគណៈកម្មាធិការរដ្ឋបាល។

## មាត្រា ៥៤
## ការចុះបញ្ជី និង អត្ថបទយថាភូត

យោងតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះត្រូវចុះបញ្ជីនៅលេខាធិការដ្ឋានអង្គការសហប្រជាជាតិតាមសំណើរបស់អគ្គលេខាធិការ។

ជាសាក្សីនៃការចុះហត្ថលេខានេះ បានទទួលសិទ្ធិត្រឹមត្រូវបានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅទីក្រុង ប្រ៊ូសែល្ស ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៣ ជាភាសាអង់គ្លេស និងបារាំងអត្ថបទទាំងពីរ មានតំលៃជាយថាភូតស្មើគ្នា មានច្បាប់ដើមតែមួយគត់ដែលត្រូវតំកល់ទុកនៅអគ្គលេខាធិការ ហើយអគ្គលេខាធិការត្រូវបញ្ជូននូវឯកសារច្បាប់ចម្លងដែលមានការបញ្ជាក់ទៅគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់យោងតាមកថាខ័ណ្ឌទី ១ និង ៣ នៃមាត្រា ៤៦ នៃអនុសញ្ញានេះ។